**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៣

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 07-Aug-2013, 16:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះតុលាការកំពូល៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

# សំណើបន្ទាន់របស់មេធាវីការពារក្ដីលោក ខៀវ សំផន សុំឲ្យបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាម

---

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

មេធាវី Jacques VERGÈS

ដាក់ជូន៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម

ចៅក្រម Agnieszka KLONOWIECKA-MILART

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម ម៉ុង មុន្នីចរិយា

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Mathilde CHIFFERT

កញ្ញា Soumeya MEDJEBEUR

កញ្ញា អ៊ួច ស្រីផាត់

កញ្ញា Vera MANUELLO

លោកស្រី សុគន្ធ មោនីកា

កញ្ញា Blandine ZELLER

ចៅក្រម យ៉ា ណារិន

ចៅក្រម Florence Ndepele Mwachande MUMBA

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. យើងជាមេធាវីការពារក្តីលោក ខៀវ សំផន ស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើអន្តរាគមន៍ភ្លាម ដើម្បីប្រកាសអំពីការរំលោភសិទ្ធិរបស់កូនក្តីយើងខ្ញុំមិនឈប់ឈរ បញ្ឈប់ការជំនុំជម្រះក្តី និងបង្គាប់ឲ្យដោះលែងកូនក្តីយើងខ្ញុំឲ្យនៅក្រៅឃុំជាបន្ទាន់។ ជាក់ស្តែង តាំងពីទទួលសំណុំរឿងអស់រយៈពេលពីរឆ្នាំកន្លះមកនេះ អង្គជំនុំជម្រះសាលាដំបូងចេះតែចេញសេចក្តីសម្រេចបន្ថែមរហូតដែលនាំឲ្យការជំនុំជម្រះក្តីនេះលែងមានភាពយុត្តិធម៌។

## I- <u>អំពីភាពអាចទទួលយកបាននៃសំណើនេះ</u>

២. ចៅក្រមមានករណីយកិច្ចធានាឲ្យកិច្ចដំណើរការនីតិវិធីមានភាពយុត្តិធម៌។ នៅក្នុងករណីមានការរំលោភបំពាន ចៅក្រមមានអំណាចមិនអាចកាត់ផ្តាច់បាន ក្នុងការបញ្ឈប់ការរំលោភបំពាននោះ។ ដោយសារអង្គជំនុំជម្រះសាលាដំបូងកំពុងធ្វើការរំលោភបំពាន មានតែអង្គជំនុំជម្រះតុលាការកំពូលប៉ុណ្ណោះដែលមានយុត្តាធិការតាមផ្លូវច្បាប់ ក្នុងការបញ្ឈប់ការរំលោភបំពាននោះ។

### ក. <u>ករណីយកិច្ចរបស់ចៅក្រមក្នុងការធានាឲ្យកិច្ចដំណើរការនីតិវិធីមានយុត្តិធម៌</u>

៣. ការជំនុំជម្រះក្តីដោយយុត្តិធម៌ គឺជាមធ្យោបាយតែមួយគត់ក្នុងការផ្តល់យុត្តិធម៌[1]។ ដូច្នេះ ចៅក្រមនៃ អ.វ.ត.ក មានទំនួលខុសត្រូវក្នុងការធានាឲ្យកិច្ចដំណើរការនីតិវិធីមានភាពយុត្តិធម៌ និងមានកាតព្វកិច្ចធ្វើយ៉ាងណាឲ្យការអនុវត្ត និងការបកស្រាយអត្ថបទច្បាប់ មានសមិតភាពនឹងសិទ្ធិមនុស្ស។

---

[1] *រដ្ឋអាជ្ញា ទល់នឹង* *Thomas Lubanga Dyilo* សាលដីកាលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចស្តីពីផលវិបាកនៃការមិនផ្តល់ភ័ស្តុតាងដោះបន្ទុក ដែលមាននៅក្នុងកិច្ចព្រមព្រៀង ដូចមានចែងនៅក្នុងមាត្រា ៥៤(៣)(ង) នៃលក្ខន្តិកៈ លើសំណើសុំព្យួរការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ និងបញ្ហាផ្សេងៗទៀតមួយចំនួនដែលបានលើកឡើង នៅក្នុងកិច្ចប្រជុំរៀបចំសវនាការ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៨ របស់អង្គជំនុំជម្រះសាលាដំបូង ១, ICC-01/04-01/06 OA 13 អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៨ (“សាលដីកា *Lubanga* ឆ្នាំ២០០៨”) កថាខណ្ឌ ៧៧។

៤. អនុលោមតាមមាត្រា ៣៣ (ថ្មី) មាត្រា ៣៥ (ថ្មី) និងមាត្រា ៣៧ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បទប្បញ្ញត្តិនៃមាត្រា ១៤ និងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អាចយកមកអនុវត្តបាន នៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី នៅចំពោះមុខ អ.វ.ត.ក។ បទប្បញ្ញត្តិទាំងនេះក៏ត្រូវបានរំឭកឡើងវិញផងដែរ នៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ក្រោមចំណងជើង *"គោលការណ៍ជាសារវន្ត"* ដែលចែងជាអាទិ៍ ថា៖

*"១. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្តន៍ និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖*

*ក- កិច្ចដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។ នីតិវិធីត្រូវធានាឲ្យបាននូវភាពដាច់ដោយឡែកពីគ្នា រវាងអាជ្ញាធរដែលទទួលបន្ទុកការចោទប្រកាន់ និងអាជ្ញាធរដែលទទួលបន្ទុកការវិនិច្ឆ័យទោស។*

*(...)*

*ឃ- ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ។ ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និងមានមេធាវីការពារ តាមការជ្រើសរើសរបស់ខ្លួន ហើយនិងនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី ត្រូវផ្តល់ព័ត៌មានដល់គេអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប។*

*(...)*

*៤. ការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ត្រូវធ្វើការជំនុំជម្រះ ក្នុងរយៈពេលមួយសមស្រប"។*

៥. អនុលោមតាមវិធាននេះ ចៅក្រមអង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក បានបញ្ជាក់ថា *"ភាពយុត្តិធម៌ គឺជាធាតុដ៏សំខាន់បំផុតដែលត្រូវពិចារណា ក្នុងគ្រប់កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក"*[2]។

## **ខ. អំណាចមិនអាចកាត់ផ្តាច់បានរបស់ចៅក្រមក្នុងការបញ្ឈប់នីតិវិធី ក្នុងករណីមានការរំលោភបំពាន**

៦. យ៉ាងណាមិញ នៅក្នុងសាលដីកាលើបណ្តឹងសាទុក្ខក្នុងរឿងក្តី LUBANGA ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ បានគូសបញ្ជាក់ថា៖

> *"ការជំនុំជម្រះក្តីដោយយុត្តិធម៌ គឺជាមធ្យោបាយតែមួយគត់ក្នុងការផ្តល់យុត្តិធម៌។ ប្រសិនបើមិនអាចជំនុំជម្រះក្តីដោយយុត្តិធម៌បានទេ កម្មវត្ថុនៃនីតិវិធីតុលាការត្រូវបរាជ័យ ហើយត្រូវបញ្ឈប់កិច្ចដំណើរការនីតិវិធី។*
>
> *(...)*
>
> *នៅពេលមានការរំលោភលើសិទ្ធិរបស់ជនជាប់ចោទ ធ្ងន់ធ្ងររហូតដល់ជនជាប់ចោទមិនអាចការពារខ្លួនបាន ក្នុងក្របខ័ណ្ឌនៃសិទ្ធិខ្លួន ការជំនុំជម្រះក្តីដោយយុត្តិធម៌មិនអាចប្រព្រឹត្តទៅបានទេ ហើយកិច្ចដំណើរការនីតិវិធីអាចត្រូវបានផ្អាក។ យោងតាមសាលដីការបស់សាលាឧទ្ធរណ៍អង់គ្លេស ក្នុងរឿងក្តី Huang ទល់នឹងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចៅក្រមមានករណីយកិច្ចធានាការពារសិទ្ធិមនុស្សជាមូលដ្ឋាន ដែលនេះជាសមត្ថកិច្ចជាក់លាក់របស់តុលាការ។ ការប្រព្រឹត្តចំពោះជនសង្ស័យ ឬជនជាប់ចោទ ដោយអយុត្តិធម៌ អាចរាំងស្ទះដល់កិច្ចដំណើរការនីតិវិធី រហូតដល់មិនអាចបំពេញធាតុផ្សំនៃការជំនុំជម្រះក្តីដោយយុត្តិធម៌។ ក្នុងកាលៈទេសៈនេះ ទោះបីជាសហគមន៍អន្តរជាតិចាប់អារម្មណ៍ខ្លាំងទៅលើការកាត់ទោសជនដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដ៏ធ្ងន់ធ្ងរបំផុតក៏ដោយ ក៏ចាំបាច់ត្រូវរក្សាប្រសិទ្ធភាពនៃនីតិវិធីតុលាការ ដែលជាឧបករណ៍ដ៏មានអនុភាពនៃយុត្តិធម៌"*[3]។

---

[2] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំព្យួរកិច្ចស៊ើបសួរ ដោយមូលហេតុរំលោភនីតិវិធី អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០ ឯកសារ **D264/2/6** កថាខណ្ឌ ១៤, សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ **D427/2/15** កថាខណ្ឌ ៧១។

[3] សាលដីកា *Lubanga* ឆ្នាំ២០០៨ កថាខណ្ឌ ៧៧-កថាខណ្ឌ ៧៨ លើកឡើងពីសាលដីកាមុនដែលបានចេញនៅក្នុងរឿងក្តីដដែល

៧. ក្នុងកាលៈទេសៈបែបនេះ និងនៅពេលមិនមានការចែងច្បាស់លាស់អំពីយន្តការសម្រាប់កែតម្រូវកាលៈទេសៈទាំងនោះ ចៅក្រមមានអំណាចមិនអាចកាត់ផ្តាច់បាន ក្នុងការបញ្ឈប់កិច្ចដំណើរការនីតិវិធី[4]។ យុត្តិសាស្ត្ររបស់ អ.វ.ត.ក បានផ្តល់សុពលភាពដល់គោលការណ៍ទាំងនេះ ដោយហេតុថា អង្គបុរេជំនុំជម្រះធ្លាប់បានប្រើប្រាស់គោលការណ៍ទាំងនេះរួចទៅហើយ សម្រាប់ជាមូលដ្ឋានបញ្ជាក់អំពីយុត្តាធិការរបស់ខ្លួន ក្នុងការពិនិត្យលើបណ្តឹងបែបនេះ[5]។

## គ. <u>យុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល</u>

៨. អង្គជំនុំជម្រះសាលាដំបូងត្រូវទទួលខុសត្រូវលើស្ថានភាព ដែលនឹងត្រូវពិពណ៌នានៅខាងក្រោម។ ក៏ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងមិនអាចសម្រេចលើការចោទប្រកាន់ពាក់ព័ន្ធនឹងការប្រព្រឹត្តរបស់ខ្លួនផ្ទាល់បានទេ ពីព្រោះវានឹងបង្កើតឲ្យមានជំទាស់ជាប្រព័ន្ធ។ អាស្រ័យហេតុនេះ មានតែអង្គជំនុំជម្រះតុលាការកំពូលប៉ុណ្ណោះដែលមានយុត្តាធិការ ក្នុងការពិនិត្យលើបញ្ហានេះ ប្រកបដោយភាពយុត្តិធម៌។ យុត្តិសាស្ត្ររបស់ អ.វ.ត.ក បានផ្តល់សុពលភាពដល់វិធីសាស្ត្រនេះ ដោយហេតុថា អង្គបុរេជំនុំជម្រះធ្លាប់បានប្រកាសរួចទៅហើយថា ខ្លួនមានយុត្តាធិការ ក្នុងការពិនិត្យលើបញ្ហានៃការចោទប្រកាន់ចំពោះការប្រព្រឹត្តរបស់សហចៅក្រមស៊ើបអង្កេត ក្នុងក្របខ័ណ្ឌនៃបណ្តឹងស្តីពីការរំលោភនីតិវិធី[6]។

---

នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៦ កថាខណ្ឌ ៣៧ និងកថាខណ្ឌ ៣៩។

[4] អំណាចមិនអាចកាត់ផ្តាច់បានក្នុងការបញ្ចប់កិច្ចដំណើរការនីតិវិធី ក្នុងករណីរំលោភនីតិវិធី គឺជាអំណាចមួយក្នុងចំណោមអំណាចនានារបស់ចៅក្រម នៅក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចមិនអាចកាត់ផ្តាច់បានរបស់ពួកគេ ដែលត្រូវបានប្រគល់ជូន យោងតាមវិធានទូទៅនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ឧទាហរណ៍ សូមមើល៖ *រឿងក្តី Sayed* លេខ CH/1C/2010/02 តុលាការពិសេសសម្រាប់ប្រទេសលីបង់ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខពាក់ព័ន្ធនឹងចៅក្រមស៊ើបសួរ ស្តីពីសមត្ថភាព និងលក្ខណៈសម្បត្តិ ក្នុងការប្តឹងទៅតុលាការ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ កថាខណ្ឌ ៤៤ ដល់កថាខណ្ឌ ៤៩។

[5] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំព្យួរកិច្ចស៊ើបសួរ ដោយមូលហេតុរំលោភនីតិវិធី អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០ ឯកសារ **D264/2/6** កថាខណ្ឌ ១០ ដល់កថាខណ្ឌ ១៤, សាលដីកាលើបណ្តឹងឧបសគ្គហេតុរបស់ ខៀវ សំផន ដែលមានគោលដៅផ្អាកភ្លាមៗ និងជាស្ថាពរ នូវនីតិវិធី ដោយមូលហេតុមានការរំលោភលើនីតិវិធី អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១១ ឯកសារ **2** កថាខណ្ឌ ៤ ដល់កថាខណ្ឌ ៦។

[6] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើបន្ទាន់របស់មេធាវីការពារក្តីលោក ខៀវ សំផន សុំឲ្យបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាម

## II- អំពីអសមត្ថភាពក្នុងការជំនុំជម្រះក្ដីដោយយុត្តិធម៌

៩. ចាប់តាំងពីពេលទទួលសំណុំរឿង នៅខែមករា ឆ្នាំ២០១១ មក អង្គជំនុំជម្រះសាលាដំបូងចេះតែព្យាយាមទុកទ្វារនៃបញ្ហាគតិយុត្ត និងបញ្ហាភ័ស្តុតាង ឲ្យនៅចំហ។ ទង្វើបែបនេះបង្កឲ្យមានភាពមិនច្បាស់លាស់ទៅលើប្រធានបទសំខាន់ៗ ហើយធ្វើឲ្យភាគីមានភាពស្រពេចស្រពិល និងភាន់ច្រឡំ។ អង្គជំនុំជម្រះសាលាដំបូងតែងតែលើកពេលពិភាក្សាគ្នា និងលើកពេលចេញសេចក្ដីសម្រេច ដែលជាការបន្ថែមកង្វល់ដល់ភាគីថែមទៀត។ ឥឡូវនេះ ខណៈពេលការជំនុំជម្រះក្ដីជិតបញ្ចប់ទៅហើយ ការបន្ថែមភាពមិនច្បាស់លាស់ទាំងនេះ នាំឲ្យការជំនុំជម្រះក្ដីគ្មានភាពយុត្តិធម៌ រហូតដល់ថ្នាក់ត្រូវបញ្ឈប់តែម្ដង។

១០. តួយ៉ាងដូចជា នៅក្នុងកិច្ចប្រជុំរៀបចំសវនាការ កាលពីថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ និងនៅក្នុងអនុស្សរណៈ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣[7] អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចដែលបង្កព្យសនកម្មខ្លាំង ពាក់ព័ន្ធនឹងលក្ខខ័ណ្ឌនៃការសួរសំណួរដល់ជនជាប់ចោទ និងការត្រៀមរៀបចំសារណា និងសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល។

១១. ម្យ៉ាងទៀត ក្នុងសវនាការស្ដីពី "ឯកសារគន្លឹះ" ពីថ្ងៃទី ២៤ ដល់ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ចំពោះប្រធានបទ "ការចូលរួមរបស់ជនជាប់ចោទក្នុងសហឧក្រិដ្ឋកម្មរួម"[8] អង្គជំនុំជម្រះសាលា

---

សំណើសុំព្យួរកិច្ចស៊ើបសួរ ដោយមូលហេតុរំលោភនីតិវិធី អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០ ឯកសារ **D264/2/6** កថាខណ្ឌ ១៧ និង ១៨, សាលដីកាលើបណ្ដឹងឧបាស្ដុតិហេតុរបស់ ខៀវ សំផន ដែលមានគោលដៅផ្អាកភ្លាមៗ និងជាស្ដាពរ នូវនីតីវិធី ដោយមូលហេតុមានការរំលោភលើនីតិវិធី អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១១ ឯកសារ **2** កថាខណ្ឌ ៥។

[7] ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/207.1** , កាលបរិច្ឆេទសម្រាប់សវនាការដេញដោលលើឯកសារជាលើកចុងក្រោយ និងសវនាការផ្សេងៗនៅក្នុងសំណុំរឿង ០០២/០១ សម្រាប់ការសួរសំណួរទៅជនជាប់ចោទ និងចម្លើយតបទៅនឹងសំណើ E263 និងសំណើ E288/1 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E288/1/1** ("អនុស្សរណៈ **E288/1/1**")។

[8] ប្រតិចារឹកសវនាការ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/211.1**, ប្រតិចារឹកសវនាការ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/212.1**, ប្រតិចារឹកសវនាការ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/213.1**។

ដំបូងបានកែប្រែការបកស្រាយដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី។ ជាក់ស្តែង អង្គជំនុំជម្រះសាលាដំបូងបានប្រកាសពីចេតនារបស់ខ្លួន ក្នុងការពិនិត្យលើការទទួលខុសត្រូវរបស់ជនជាប់ចោទចំពោះគោលនយោបាយទាំងអស់ ដូចមានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺមិនមែនចំពោះតែគោលនយោបាយពីរនោះទេ។ ក៏ប៉ុន្តែ រហូតមកទល់នឹងត្រឹមនេះ អង្គជំនុំជម្រះសាលាដំបូងមិនធ្លាប់បានជូនដំណឹងដល់ភាគីអំពីចេតនាបែបនេះទាល់តែសោះ ហើយក៏មិនធ្លាប់បានផ្តល់មធ្យោបាយឱ្យភាគី ក្នុងការឆ្លើយតបទៅនឹងការចោទប្រកាន់ជាមូលដ្ឋានទាំងនេះឡើយ។

១២. បន្ទាប់ពីមានសេចក្តីសម្រេចជាបន្តបន្ទាប់ លោក ខៀវ សំផន ត្រូវបង្ខំចិត្តក្នុងការគូសបញ្ជាក់ថាគាត់គ្មានលទ្ធភាពការពារខ្លួន នៅចំពោះមុខចៅក្រមឡើយ ហើយក៏គ្មានប្រយោជន៍អ្វីដែលគាត់ត្រូវឆ្លើយតបទៅនឹងសំណួររបស់ចៅក្រម និងភាគី នោះដែរ[9]។

១៣. នៅថ្ងៃទី ២៣ និងថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបិទកិច្ចពិភាក្សាដេញដោល ហើយបានកំណត់កាលវិភាគចុងក្រោយ[10]។ ការបិទសវនាការបានបិទទ្វារជាស្ថាពរមិនឱ្យមានពិភាក្សាដេញដោលលើបញ្ហាទាំងនេះឡើយ។

១៤. ការចេញសេចក្តីសម្រេចជាបន្តបន្ទាប់ទាំងនេះ គឺជាដំណើរវិវត្តយឺតៗឈានទៅរកភាពអយុត្តិធម៌។ នេះជាការបង្ហាញឱ្យឃើញអំពីការរំលោភបំពានធ្ងន់ធ្ងរដល់ចំណុចកំពូល ទៅលើសិទ្ធិរបស់លោក ខៀវ សំផន ដូចជា សិទ្ធិក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់ សិទ្ធិទទួលបានការជូនដំណឹងអំពីបទចោទប្រឆាំងនឹងគាត់ សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន សិទ្ធិទទួលបានការជំនុំជម្រះក្តីចំពោះមុខ សិទ្ធិបញ្ចេញមតិ សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយតុលាការអនាគតិ។

១៥. នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូលបានផ្ញើជូនភាគីនូវសេចក្តីសង្ខេប

---

[9] សេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ពាក់ព័ន្ធនឹងការសួរដេញដោលជនជាប់ចោទ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ **E288/4** (“សេចក្តីជូនដំណឹង **E288/4**”)។

[10] ប្រតិចារឹកសវនាការ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ **E1/227.1**, ការបញ្ជាក់ពីកាលបរិច្ឆេទនៃការដាក់សារណា និងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ **E295**។

សំអាងហេតុនៃសេចក្ដីសម្រេចរបស់ខ្លួនលើបណ្ដឹងសាទុក្ខ ប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីរស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធបណ្ដឹងសាទុក្ខដោយសំអាងហេតុថា នៅដំណាក់កាលនេះនៃការជំនុំជម្រះក្ដី ការពង្រីកវិសាលភាពនៃសំណុំរឿង ០០២/០១ នឹងនាំឲ្យមានការពន្យារនីតិវិធីដោយមិនសមហេតុផល។ ជាការពិត ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលគិតថា ការជំនុំជម្រះក្ដីសំណុំរឿង ០០២/០១ មិនមានភាពតំណាងគ្រប់គ្រាន់ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងគ្មានលទ្ធភាពពិនិត្យលើបទចោទបន្ថែមទៀតនោះទេ[11]។ ហេតុដូច្នេះហើយបានជា អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ឲ្យការិយាល័យរដ្ឋបាលស្វែងរកលទ្ធភាពក្នុងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ ដើម្បីជំនុំជម្រះក្ដីសំណុំរឿង ០០២/០២[12]។

១៦. សេចក្ដីសម្រេចនេះរបស់អង្គជំនុំជម្រះតុលាការកំពូលបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមិនបានគោរពតាមការណែនាំ ក្នុងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣[13] នោះទេ គឺគ្រាន់តែបន្ទន់ឥរិយាបថ ដោយសារតែស្ថានភាពមិនអាចគ្រប់គ្រងបាន។ សេចក្ដីសម្រេចនេះកាន់តែបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងគ្មានសមត្ថភាព ឬគ្មានឆន្ទៈក្នុងការជំនុំជម្រះក្ដីដោយយុត្តិធម៌ឡើយ។ ដូច្នេះ ការបង្កើតក្រុមប្រឹក្សាជំនុំជម្រះថ្មីសម្រាប់ពិនិត្យលើបទចោទផ្សេងទៀត នៅក្នុងការជំនុំជម្រះក្ដីវគ្គបន្ទាប់ នឹងមិនអាចលុបបំបាត់ព្យសនកម្មជាច្រើនដែលលោក ខៀវ សំផន បានទទួលរង នៅក្នុងការជំនុំជម្រះក្ដីសំណុំរឿង ០០២/០១ នោះទេ។

១៧. លើសពីនេះទៅទៀត មូលដ្ឋានសម្រាប់បង្កើតក្រុមប្រឹក្សាជំនុំជម្រះថ្មីដើម្បីបន្តការកាត់សេចក្ដីសំណុំរឿង ០០២ មិនមានភាពច្បាស់លាស់នោះទេ។ យើងនឹងមើលឃើញថា តាមពិតទៅ ប្រសិនបើត្រូវ

---

[11] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ (សេចក្ដីសង្ខេបសំអាងហេតុ) អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ **E284/4/7** កថាខណ្ឌ ១០ និងកថាខណ្ឌ ១១។

[12] ដីកាទាក់ទងនឹងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ **E284/4/7/1**។

[13] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ (សេចក្ដីសង្ខេបសំអាងហេតុ) អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ **E284/4/7** កថាខណ្ឌ ៩។

បង្កើតឡើងនៅថ្ងៃណាមួយមែននោះ គឺគ្រាន់តែជាលេសទេ ក្រុមប្រឹក្សាជំនុំជម្រះទីពីរគ្មានអ្វីត្រូវជំនុំជម្រះទៀតនោះទេ...។

១៨. ដូច្នេះ ព្យសនកម្មដែលកើតចេញពីការជំនុំជម្រះក្ដីសំណុំរឿង ០០២/០១ នឹងបន្តសាយភាយទៅដល់ការជំនុំជម្រះក្ដីវគ្គបន្ទាប់ទៀត ឬអាចថាការប្រកាសពីការជំនុំជម្រះក្ដីសំណុំរឿង ០០២/០២ គ្រាន់តែជាឧបាយកលដោះខ្លួន សំដៅបញ្ចប់ដោយស្ងាត់ស្ងៀមនូវការជំនុំជម្រះក្ដីសំណុំរឿង ០០២/០១ ដោយលាក់បាំងមិនឱ្យមតិអន្តរជាតិដឹងអំពីស្ថានភាពពិតប្រាកដរបស់តុលាការមួយ ដែលអសមត្ថភាពក្នុងការបញ្ចប់បេសកកម្មរបស់ខ្លួន។ ក្នុងករណីទាំងពីរនេះ ព្យសនកម្មដែលលោក ខៀវ សំផន ទទួលរង មានភាពធ្ងន់ធ្ងររហូតដល់ត្រូវបញ្ឈប់កិច្ចដំណើរការនីតិវិធីជាបន្ទាន់ ហើយត្រូវដោះលែងលោក ខៀវ សំផន ឱ្យនៅក្រៅឃុំ។

## i. <u>អង្គជំនុំជម្រះសាលាដំបូងអសមត្ថភាពក្នុងការជំនុំជម្រះក្ដីដោយយុត្តិធម៌</u>

១៩. នៅទីបំផុត ភាពមិនស៊ីសង្វាក់គ្នានៃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បានបង្កើតឱ្យមានអស្ថិរភាពគតិយុត្តិមិនអាចជួសជុលបាន។ ភាពមិនស៊ីសង្វាក់គ្នានេះបានស្ដែងឡើង នៅក្នុងការកំណត់វិសាលភាពនៃសំណុំរឿង ០០២/០១ **(ក)** ដែលបណ្ដាលឱ្យមានភាពមិនច្បាស់លាស់ទាំងស្រុង ចំពោះការពិនិត្យមើលការទទួលខុសត្រូវរបស់ជនជាប់ចោទ ពាក់ព័ន្ធនឹងការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម **(ខ)** និងបណ្ដាលឱ្យមានអស្ថិរភាពគតិយុត្តិច្បាស់ក្រឡែត និងការរំលោភមិនអាចប្រែកែកបានទៅលើសិទ្ធិជាមូលដ្ឋានរបស់លោក ខៀវ សំផន **(គ)**។

## ក. <u>អង្គជំនុំជម្រះសាលាដំបូងអសមត្ថភាពក្នុងការកំណត់វិសាលភាពនៃសំណុំរឿង ០០២/០១</u>

### ១) <u>ភាពចម្រូងចម្រាសគ្នានៃសេចក្ដីសម្រេច ដែលមិនត្រូវបានដោះស្រាយទាល់តែសោះ</u>

២០. ប្រវត្តិនីតិវិធីនៃការបំបែកបទចោទបង្ហាញឱ្យយើងឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនធ្លាប់មានសមត្ថភាព ឬមិនធ្លាប់ចង់កំណត់វិសាលភាពសំណុំរឿង ០០២/០១ ឱ្យបានច្បាស់ ទាល់តែសោះ។ ឧទាហរណ៍ សំណួរដែលសួរចង់ដឹងថា តើគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ក្រៅពី

ការជម្លៀសប្រជាជន ស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះក្តីវគ្គទីមួយ ដែរឬទេ មិនដែលទទួលបានចម្លើយជាក់ច្បាស់ទាល់តែសោះ។ នៅក្នុងចម្លើយទៅនឹងសំណួររបស់ភាគីលើប្រធានបទនេះ អង្គជំនុំជម្រះសាលាដំបូងតែងតែផ្តល់អាទិភាពទៅលើដំណោះស្រាយអន្តរកាល មិនច្បាស់លាស់ និងផ្ទុយគ្នា។ ឥឡូវនេះ នៅសល់តែប៉ុន្មានសប្តាហ៍ទៀតដល់ពេលដាក់សារណាសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល អង្គជំនុំជម្រះសាលាដំបូងនៅតែមិនប្រកាន់គោលជំហរច្បាស់លាស់ដដែល។ ប្រការនេះរំលោភយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិរបស់មេធាវីការពារក្តី។

២១. ជាដំបូង នៅក្នុងកិច្ចប្រជុំរៀបចំសវនាការ កាលពីខែ មេសា ឆ្នាំ ២០១១ និងសវនាការបឋម កាលពីខែ មិថុនា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសពីចេតនារបស់ខ្លួន ក្នុងការពិនិត្យលើអង្គហេតុ ដែលជាកម្មវត្ថុនៃការជំនុំជម្រះក្តីសំណុំរឿង ០០២ តាមលំដាប់លំដោយដូចតទៅ៖ ១) រចនាសម្ព័ន្ធនៃកម្ពុជាប្រជាធិបតេយ្យ ២) តួនាទីរបស់ជនជាប់ចោទនីមួយៗ នៅមុនពេលបង្កើតកម្ពុជាប្រជាធិបតេយ្យ ៣) តួនាទីរបស់ជនជាប់ចោទនីមួយៗនៅក្នុងកម្ពុជាប្រជាធិបតេយ្យ និង ៤) គោលនយោបាយបង្កើតឡើងដោយកម្ពុជាប្រជាធិបតេយ្យ[14]។

២២. ក្រោយមកទៀត នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី លើកទីមួយ[15]។ ដីកានោះសម្រេចថា អង្គហេតុដែលត្រូវលើកយកមកដេញដោលនៅក្នុងការជំនុំជម្រះក្តីវគ្គទីមួយ មិនពាក់ព័ន្ធនឹង *"សហករណ៍ ការដ្ឋាន មន្ទីរសន្តិសុខ និងអង្គហេតុនៃការជម្លៀសប្រជាជន ដំណាក់កាលទីបី"*[16] នោះទេ គឺពាក់ព័ន្ធតែនឹងការជម្លៀសប្រជាជន ដំណាក់កាលទីមួយ និងទីពីរ ប៉ុណ្ណោះ[17]។ នៅក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី លើកទីមួយ អង្គជំនុំជម្រះសាលាដំបូងបានយកចិត្តទុកដាក់ក្នុងការរំឮកថា នៅក្នុងកិច្ច

---

[14] ប្រតិចារិកសវនាការ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ ឯកសារ **E1/2.1** ទំព័រ ៥៦ បន្ទាត់ ២១ ដល់ទំព័រ ៥៧ បន្ទាត់ ៨ (ភាសាបារាំង), ប្រតិចារិកសវនាការ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ **E1/4.1** ទំព័រ ៧ បន្ទាត់ ១៦ ដល់ទំព័រ ៨ បន្ទាត់ ៤ (ភាសាបារាំង)។

[15] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ **E124**។

[16] ដូចយោងខាងលើ កថាខណ្ឌ ៧។

[17] ដូចយោងខាងលើ កថាខណ្ឌ ៥។

ប្រជុំរៀបចំសវនាការ និងសវនាការបឋម អង្គជំនុំជម្រះសាលាដំបូងមិនទាន់បានសម្រេចពាក់ព័ន្ធនឹងការបំបែកបទចោទ ក្នុងការជំនុំជម្រះក្ដីសំណុំរឿង ០០២ នោះទេ។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះបានស្នើថា អង្គហេតុទាំងបួនប្រភេទ ដែលបានកំណត់កាលពីខែ មេសា និងខែ មិថុនា ឆ្នាំ ២០១១ នឹងត្រូវកម្រិតត្រឹមតែឧក្រិដ្ឋកម្មដែលជាកម្មវត្ថុនៃការជំនុំជម្រះក្ដីវគ្គទីមួយប៉ុណ្ណោះ[18]។ ដូច្នេះ មកទល់នឹងត្រឹមដំណាក់កាលនេះ គ្មានអ្វីអាចឲ្យយើងគិតបានថា អង្គជំនុំជម្រះសាលាដំបូងគ្រោងពិនិត្យលើការចូលរួមរបស់ជនជាប់ចោទក្នុងគោលនយោបាយឧក្រិដ្ឋទាំងមូល ដូចមានចែងនៅក្នុងដីកាដំណោះស្រាយ នោះទេ។

២៣. នៅថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានដាក់សំណើសុំឲ្យពិចារណាឡើងវិញលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ដោយបន្ទោសដល់អង្គជំនុំជម្រះសាលាដំបូងថាមិនមានភាពតំណាងអង្គហេតុគ្រប់គ្រាន់ ដូចមានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[19]។ នៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើនេះ តាមរយៈសេចក្ដីសម្រេចមួយដែលឆ្លុះបញ្ចាំងរួចទៅហើយអំពីអសមត្ថភាពរបស់ខ្លួន ក្នុងការកំណត់វិសាលភាពសំណុំរឿង ០០២/០១ ឲ្យបានសមហេតុផល។

២៤. ជាក់ស្ដែង ម្យ៉ាង អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីប្រកាសស្រពេចស្រពិល៖

> *"ផ្នែកដំបូងៗនៃសវនាការនឹងផ្ដោតការយកចិត្តទុកដាក់ទៅលើតួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទ ទាក់ទងទៅនឹងគោលនយោបាយពាក់ព័ន្ធ ដូចមានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូល ប៉ុន្តែ នឹងផ្ដល់សេចក្ដីលម្អិតនៃការពិចារណាអំពីអង្គហេតុនៅក្នុងការជំនុំជម្រះក្ដីវគ្គទីមួយ ជាសំខាន់ទៅលើចំណុចពិសេសនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលប៉ះពាល់ដល់ជនរងគ្រោះស្ទើរតែទាំងអស់នៃរបបកម្ពុជាប្រជាធិបតេយ្យ គឺការជម្លៀសដោយបង្ខំ ដំណាក់កាលទីមួយ និងទីពីរ"*[20]។

---

[18] ដូចយោងខាងលើ។

[19] សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញអំពី "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង" ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១១ ឯកសារ **E124/2**។

[20] សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ ចុះ

សំណើបន្ទាន់របស់មេធាវីការពារក្ដីលោក ខៀវ សំផន សុំឲ្យបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាម

២៥. ម្យ៉ាងទៀត អង្គជំនុំជម្រះសាលាដំបូងបានភ្ជាប់ទៅនឹងសេចក្តីសម្រេចរបស់ខ្លួននូវឧបសម្ព័ន្ធមួយ ដើម្បីកំណត់ផ្នែកពាក់ព័ន្ធនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ សម្រាប់ការជំនុំជម្រះក្តីសំណុំរឿង ០០២/០១។ នៅបន្ទាត់ចុងក្រោយនៃកថាខណ្ឌ ៣ នៃឧបសម្ព័ន្ធនេះ ក្រោមចំណងជើងថា "តួនាទីរបស់ជនជាប់ចោទ" មានការបញ្ជាក់ថា៖

*ការចូលរួមក្នុងផែនការរួម (<u>កម្រិតត្រឹមការជម្លៀសដោយបង្ខំ ដំណាក់កាលទីមួយ និងទីពីរ</u>)"*[21]។

២៦. សហព្រះរាជអាជ្ញាបានលើកឡើងនូវលទ្ធភាព នៃភាពខុសគ្នារវាងខ្លឹមសារនៃសេចក្តីសម្រេច និងខ្លឹមសារនៃឧបសម្ព័ន្ធ ហើយក៏បានផ្ញើជូនអង្គជំនុំជម្រះសាលាដំបូងនូវសំណើសុំបំភ្លឺលើបញ្ហាដែលនឹងត្រូវអនុញ្ញាតនៅក្នុងការជំនុំជម្រះក្តីវគ្គទីមួយ ពាក់ព័ន្ធនឹងគោលនយោបាយទាំងប្រាំ ដែលបង្កើតបានជាសហឧក្រិដ្ឋកម្មរួម និងតួនាទី និងការចូលរួមរបស់ជនជាប់ចោទក្នុងគោលនយោបាយទាំងនេះ[22]។ សហព្រះរាជអាជ្ញាបានស្នើថា បើមានភាពមិនស៊ីសង្វាក់គ្នារវាងខ្លឹមសារនៃសេចក្តីសម្រេច (ឯកសារ E124/7 កថាខណ្ឌ ១១) និងខ្លឹមសារនៃឧបសម្ព័ន្ធ (ឯកសារ E124/7.1) ត្រូវដោះស្រាយដោយយកតាមខ្លឹមសារនៃសេចក្តីសម្រេច ដែលហាក់ដូចជាមានន័យទូលំទូលាយជាង[23]។ អង្គជំនុំជម្រះសាលាដំបូងមិនបានសម្រេចលើសំណើសុំបំភ្លឺនេះទេ ហើយក៏មិនបានដោះស្រាយភាពផ្ទុយគ្នារវាងសេចក្តីសម្រេចរបស់ខ្លួន ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ និងឧបសម្ព័ន្ធនោះដែរ។

## ២) <u>ការប្រកាន់យកដំណោះស្រាយដោះខ្លួន</u>

---

ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារ **E124/7** ("សេចក្តីសម្រេច **E124/7**") កថាខណ្ឌ ១១។

[21] ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា មានចំណងជើងថា "បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូង នៅក្នុងសំណុំរឿង ០០២" ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារ **E124/7.1** កថាខណ្ឌ ៣។

[22] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យបញ្ជាក់ពីវិសាលភាពនៃសវនាការដំបូង ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ **E124/9** កថាខណ្ឌ ៤ និងកថាខណ្ឌបន្តបន្ទាប់។

[23] ដូចយោងខាងលើ កថាខណ្ឌ ១៤។

២៧. នៅទីបញ្ចប់ តាមរយៈអនុស្សរណៈដ៏សាមញ្ញមួយ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចយកដំណោះស្រាយកណ្ដាលមួយ ដោយបញ្ជាក់អះអាងឡើងវិញថាការពិនិត្យភស្តុតាង នៅក្នុងក្របខ័ណ្ឌនៃការជំនុំជម្រះក្តីសំណុំរឿង ០០២/០១ នឹងផ្តោតតែទៅលើការជម្លៀសប្រជាជនដោយបង្ខំ (ដំណាក់កាលទីមួយ និងទីពីរ) ហើយនឹងអាចមានការសួរដេញដោលផងដែរទៅលើគោលនយោបាយផ្សេងទៀត *"គឺដើម្បីតែវាយតម្លៃអំពីរបៀបដែលគោលនយោបាយទាំងនេះត្រូវបានបង្កើតឡើងជាលំដាប់ប៉ុណ្ណោះ"*[24]។

២៨. ចំពោះការពិនិត្យលើបរិបទប្រវត្តិសាស្ត្រ អង្គជំនុំជម្រះសាលាដំបូងបានអះអាងថា បើសិនមានការពិចារណាឃើញថា ការអនុវត្តគោលនយោបាយមួយចំនួននៃគោលនយោបាយទាំងប្រាំរបស់កម្ពុជាប្រជាធិបតេយ្យ បានចាប់ផ្តើមមុនខែ មេសា ឆ្នាំ ១៩៧៥ វិសាលភាពនៃការសួរសំណួរទៅកាន់ជនជាប់ចោទអាចគ្រោងថានឹងពង្រីកទៅដល់គោលនយោបាយទាំងនេះបាន ប៉ុន្តែ *"កុំសួរលម្អិត"*។ នៅក្នុងអនុស្សរណៈនេះ អង្គជំនុំជម្រះសាលាដំបូងក៏បានរំឭកផងដែរថា បញ្ហានៃការអនុវត្តជាក់ស្តែងនូវគោលនយោបាយអាចត្រូវបានលើកឡើងសម្រាប់តែការជម្លៀសប្រជាជន ដំណាក់កាលទីមួយ និងទីពីរ។ អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ថា៖ *"គឺមានន័យថា ភាគីត្រូវសួរផ្តោតតែទៅលើអង្គហេតុពាក់ព័ន្ធនឹងការជំនុំជម្រះក្តីវគ្គទីមួយ"* *"ពីព្រោះមិនអនុញ្ញាតឲ្យសួរលើអង្គហេតុផ្សេងដែលនឹងត្រូវពិភាក្សាដេញដោលក្នុងការជំនុំជម្រះក្តីវគ្គក្រោយនៃសំណុំរឿង ០០២ ឡើយ"*[25]។

២៩. ជាចុងក្រោយ នៅក្នុងអនុស្សរណៈនេះ អង្គជំនុំជម្រះសាលាដំបូងមិនបានឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ដែលសុំឱ្យបញ្ជាក់ថា តួនាទីរបស់ជនជាប់ចោទនឹងត្រូវពិនិត្យ ទាក់ទិននឹងគោលនយោបាយពាក់ព័ន្ធទាំងអស់នោះទេ។ ផ្ទុយទៅវិញ ដោយសារតែអង្គជំនុំជម្រះសាលាដំបូងបានប្រកាសប្រាប់ភាគីរួចទៅហើយថា មិនអនុញ្ញាតឲ្យសួរសំណួរអំពីគោលនយោបាយដែលមិនពាក់ព័ន្ធនឹងការជម្លៀសប្រជាជន (លើកលែងតែក្នុងករណីពិសេស ក្នុងក្របខណ្ឌនៃសវនាការស្តីពី

---

[24] ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗ មុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ **E141** ("អនុស្សរណៈ **E141**") ទំព័រ ៣។

[25] ដូចយោងខាងលើ។

"បរិបទប្រវត្តិសាស្ត្រ") គ្មានអ្វីអាចឲ្យមេធាវីការពារក្តីសន្និដ្ឋានថា ការទទួលខុសត្រូវរបស់ជនជាប់ចោទ ចំពោះគោលនយោបាយទាំងអស់នឹងចូលក្នុងវិសាលភាពនៃការជំនុំជម្រះក្តីវគ្គទីមួយនៅពេលក្រោយ នោះទេ។

៣០. នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូងនូវសំណើសុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០១[26]។ មិនដល់ប្រាំបួនខែផង គឺនៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានឆ្លើយតបតាមរយៈអនុស្សរណៈ។ ក្នុងអនុស្សរណៈនេះ អង្គជំនុំជម្រះបានពង្រីកវិសាលភាពនៃការជំនុំជម្រះក្តីទៅដល់ទីតាំងទួលពោធិ៍ជ្រៃ[27]។ សេចក្តីសម្រេចនេះអមដោយឧបសម្ព័ន្ធ E124/7.3 ដែលបានបញ្ជាក់ម្តងទៀតនូវវិធានដដែលនៅក្នុងឧបសម្ព័ន្ធ E124/7.1 ខាងលើ ដែលថាមានតែគោលនយោបាយពាក់ព័ន្ធនឹងការជម្លៀសប្រជាជន និងការចាត់ *"វិធានការដាក់លាក់"* ចំពោះអតីតអ្នកទទួលខុសត្រូវនៃរបបសាធារណរដ្ឋខ្មែរប៉ុណ្ណោះ ដែលស្ថិតក្នុងវិសាលភាពនៃការជំនុំជម្រះក្តីសំណុំរឿង ០០២/០១។ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា៖

> *"ចំពោះទម្រង់នៃការទទួលខុសត្រូវ ដែលកើតចេញពីសហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា កថាខណ្ឌ ១៥២១ ដល់កថាខណ្ឌ ១៥២៥ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ មានភាពពាក់ព័ន្ធ ក្នុងក្របខ័ណ្ឌនៃការជំនុំជម្រះក្តីសំណុំរឿង ០០២/០១ (លើកលែងតែទាក់ទិននឹងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងវាក្យខណ្ឌដែលមានចំណងជើងថា ការបង្កើត និងការប្រព្រឹត្តទៅនៃសហករណ៍ និងការដ្ឋានការអប់រំសមាសភាពមិនល្អ ការកម្ទេចខ្មាំងក្នុង និងក្រៅបក្ស និងការគ្រប់គ្រងលើការរៀបអាពាហ៍ពិពាហ៍) ដោយពិនិត្យមើលតែទាហាន និងមន្ត្រីរដ្ឋការនៃសាធារណរដ្ឋខ្មែរ ចំពោះវាក្យខណ្ឌ ដែលមានចំណងជើងថា ការចាត់វិធានការដាក់លាក់ប្រឆាំងនឹងក្រុមគោលដៅ*

[26] សំណើរបស់សហព្រះរាជអាជ្ញា សុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម នៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ ឯកសារ **E163** កថាខណ្ឌ ៧។

[27] សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ ឯកសារ **E163/5** កថាខណ្ឌ ៣។

*មួយចំនួន ជាពិសេស ជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិក និងអតីតអ្នកទទួលខុសត្រូវ (មន្ត្រីរដ្ឋការ យោធា និងគ្រួសាររបស់ពួកគេ) នៃសាធារណរដ្ឋខ្មែរ"*[28]។

៣១. មេធាវីការពារក្តី ខៀវ សំផន យល់ឃើញយ៉ាងត្រឹមត្រូវថា ខ្លឹមសារនៃឧបសម្ព័ន្ធថ្មី E124/7.3 នេះបញ្ចប់ភាពចម្រូងចម្រាសពីមុន ដែលកើតឡើងដោយសារភាពមិនស៊ីសង្វាក់គ្នារវាងខ្លឹមសារនៃសេចក្តីសម្រេច E124/7 និងខ្លឹមសារនៃឧបសម្ព័ន្ធ E124/7.1។ ចាប់ពីពេលនេះតទៅ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់យ៉ាងច្បាស់ថា ក្នុងការជំនុំជម្រះក្តីវគ្គទីមួយ តួនាទីរបស់ជនជាប់ចោទនឹងមិនត្រូវពិនិត្យ ពាក់ព័ន្ធនឹងគោលនយោបាយទាំងអស់ ដែលមានកំណត់នៅក្នុងដីកាដំណោះស្រាយនោះទេ។ ជាក់ស្តែង ប្រសិនបើអានរួមគ្នាជាមួយអនុស្សរណៈ E141 ដែលក្នុងនោះ អង្គជំនុំជម្រះសាលាដំបូងបានចង្អុលបង្ហាញថា ក្នុងការជំនុំជម្រះក្តីវគ្គទីមួយ ភាគីមិនត្រូវបានអនុញ្ញាតឱ្យសួរអំពីអង្គហេតុ ដែលនឹងត្រូវពិភាក្សាដេញដោលក្នុងវគ្គក្រោយៗ ឧបសម្ព័ន្ធនេះហាក់ដូចជាច្បាស់។

៣២. នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាបំបែកបទចោទ លើកទីពីរ[29]។ ផ្នែកសំអាងហេតុនៃសេចក្តីសម្រេចនេះ ដែលពាក់ព័ន្ធនឹងវិសាលភាពនៃការជំនុំជម្រះក្តីសំណុំរឿង ០០២/០១ មានដូចតទៅ៖

> *"តាមសំអាងហេតុខាងលើ អង្គជំនុំជម្រះសាលាដំបូង៖ [...] សម្រេចថា វិសាលភាពនៃមូលដ្ឋាននៃបទល្មើសក្នុងសំណុំរឿង ០០២/០១ មាននៅក្នុងផ្នែកនានានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទាក់ទងនឹងការផ្លាស់ទីលំនៅដោយបង្ខំ ដំណាក់កាលទីមួយ និងទីពីរ ការសម្លាប់មនុស្សដែលត្រូវបានប្រព្រឹត្ត នៅទួលពោធិ៍ជ្រៃដែលកើតមានភ្លាមៗ ក្រោយថ្ងៃជម្លៀស*

[28] ឧបសម្ព័ន្ធ៖ "បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿង០០២ ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ ០០២/០១ (E163) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ ឯកសារ **E124/7.3** កថាខណ្ឌ ៥។

[29] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣" ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **E284** ("សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី **E284**")។

*ប្រជាជនពីទីក្រុងភ្នំពេញ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលពាក់ព័ន្ធដទៃទៀត គឺជាបណ្តាកថាខណ្ឌទាំងឡាយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿង ០០២ ដែលបានបញ្ជូនទៅភាគី កាលពីលើកមុន ក្នុងឯកសារ E124/7.3 "*[30]។

៣៣. ដូច្នេះ ដីកានេះហាក់ដូចជាគោរពតាមវិសាលភាពនៃការជំនុំជម្រះក្តី ដែលបានកំណត់ពីមុន។ ហេតុនេះហើយបានជាលោក ខៀវ សំផន មិនបានប្តឹងសាទុក្ខនោះទេ។

៣៤. ក៏ប៉ុន្តែ នៅក្នុងសវនាការស្តីពីឯកសារគន្លឹះ កាលពីថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៣ មេធាវីការពារក្តីលោក ខៀវ សំផន បានជំទាស់ទៅនឹងឯកសារមួយដែលសហព្រះរាជអាជ្ញាបានបង្ហាញ ដោយហេតុថា ឯកសារនោះស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះក្តី ដែលឧបសម្ព័ន្ធ E124/7.3 បានកំណត់[31]។ គួរឲ្យភ្ញាក់ផ្អើលណាស់ លោកស្រីចៅក្រម បានឆ្លើយតបទៅនឹងការជំទាស់នោះថា៖

*"អង្គជំនុំជម្រះសាលាដំបូងតែងតែបញ្ជាក់ជានិច្ចថា ភាគីអាចបង្ហាញភ័ស្តុតាងពាក់ព័ន្ធនឹងអត្ថិភាពនៃគោលនយោបាយទាំងប្រាំនេះបាន ប៉ុន្តែភ័ស្តុតាងអំពីការអនុវត្តគោលនយោបាយទាំងនេះត្រូវកម្រិតត្រឹមតែគោលនយោបាយនៃការជម្លៀសដោយបង្ខំប៉ុណ្ណោះ។ ហេតុនេះ សហព្រះរាជអាជ្ញាត្រូវកម្រិតការបង្ហាញឯកសាររបស់ខ្លួនត្រឹមដែនកំណត់នេះ"*[32]។

៣៥. ដូចយើងទើបឃើញពីខាងលើហើយ អង្គជំនុំជម្រះសាលាដំបូងមិនធ្លាប់បាន *"បញ្ជាក់ថាភាគីអាចបង្ហាញភ័ស្តុតាងពាក់ព័ន្ធនឹងអត្ថិភាពនៃគោលនយោបាយទាំងប្រាំនោះទេ"*។ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ចំណុចនេះ យើងគ្រាន់តែអានអនុស្សរណៈ E141 ចុះខែ តុលា ឆ្នាំ ២០១១ ដែលក្នុងនោះ អង្គជំនុំ

---

[30] ដូចយោងខាងលើ ផ្នែកសម្រេចសេចក្តី កថាខណ្ឌ ៣។ ក៏ប៉ុន្តែ គួររំឭកថា ផ្នែកនៃឧបសម្ព័ន្ធ E124/7.3 ពាក់ព័ន្ធនឹងការចូលរួមរបស់លោក ខៀវ សំផន ក្នុង "ផែនការរួម" បញ្ជាក់អំពី៖ "ការចូលរួមក្នុងផែនការរួម-ការផ្លាស់ទីលំនៅប្រជាជន (កម្រិតត្រឹមដំណាក់កាលទី ១ និងទី ២) (១១៥៣-១១៦២) និងវិធានការផ្សេងៗដែលបានធ្វើឡើងប្រឆាំងនឹងក្រុមជាក់លាក់នានា (កម្រិតត្រឹមវិធានការដែលផ្តោតចំពោះអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ) (កថាខណ្ឌ ១១៨១ ដល់ ១១៩៣)"។

[31] ប្រតិចារឹកសវនាការ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/211.1** ទំព័រ ៩៤ បន្ទាត់ ១៨ ដល់ទំព័រ ៩៧ បន្ទាត់ ២០ (ភាសាបារាំង)។

[32] ប្រតិចារឹកសវនាការ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/211.1** ទំព័រ ១០៣ បន្ទាត់ ៤-១៣ (ភាសាបារាំង)។

ជម្រះសាលាដំបូងបានរំឭកដល់ភាគីថា *"ការពិនិត្យភ័ស្តុតាង ក្នុងក្របខ័ណ្ឌនៃការជំនុំជម្រះក្តីវគ្គទីមួយ ផ្តោតតែទៅលើការជម្លៀសប្រជាជនដោយបង្ខំ (ដំណាក់កាលទីមួយ និងទីពីរ) ប៉ុណ្ណោះ"*[33]។ ជាថ្មីម្តងទៀត ការអះអាងរបស់ចៅក្រមបង្ហាញអំពីអសមត្ថភាពរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការកំណត់សេចក្តីណែនាំច្បាស់លាស់ សម្រាប់ជាក្របខ័ណ្ឌគតិយុត្តិរឹងមាំ និងអាចប្រមើលមើលបាន។ ការអះអាងខុសនេះក៏បានរុញច្រានការជំនុំជម្រះក្តីឱ្យធ្លាក់ទៅក្នុងភាពស្រពេចស្រពិល និងភាពមិនស៊ីសង្វាក់គ្នា៖ នៅក្នុងបរិបទនៃការពិនិត្យលើការទទួលខុសត្រូវរបស់ជនជាប់ចោទចំពោះការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ការញែកឱ្យដាច់ពីគ្នារវាង "អត្ថិភាព" និង "ការអនុវត្ត" គោលនយោបាយ មិនអាចធ្វើបានទេ គឺមានតែបំផ្លាញភាពសមហេតុផលនៃ "ការជំនុំជម្រះក្តីវគ្គតូចៗ" ទាំងមូលប៉ុណ្ណោះ។

## ខ. <u>ភាពមិនច្បាស់លាស់ក្នុងការបង្ហាញពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទនៅក្នុងការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម</u>

### ១) <u>អង្គៈមិនអាចទទួលយកបានក្នុងការសម្រួលដល់ភារកិច្ចផ្តល់ដល់សហព្រះរាជអាជ្ញាក្នុងការបង្ហាញភស្តុតាងនៃការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមរបស់ជនជាប់ចោទ</u>

៣៦. សារបានបង្ហាញឱ្យឃើញថាអង្គជំនុំជម្រះបានទុកឱ្យស្រពេចស្រពិល និងបើកចំហ អស់រយៈពេលយ៉ាងយូរ នូវចម្លើយរបស់ខ្លួនតបទៅសំណួរដែលសួរថា តើគោលនយោបាយដែលមិនទាក់ទងនឹងការជម្លៀសដោយបង្ខំ មានតួនាទីអ្វីនៅក្នុងសំណុំរឿង ០០២/០១ នោះ។ រហូតទាល់តែសល់តែពីរបីសប្តាហ៍ទៀត សំណុំរឿងនេះឈានចូលដល់ទីបញ្ចប់ទើបអង្គជំនុំជម្រះបង្ខំចិត្តលាតត្រដាងនូវអ្វីដែលខ្លួនតែងតែគេចវេះមិនព្រមចង្អុលបង្ហាញពីមុនមក។ អង្គជំនុំជម្រះបានធ្វើការបែងចែកដែលមិនធ្លាប់មានពីមុន រវាងតួនាទីរបស់ជនជាប់ចោទក្នុងការកំណត់គោលនយោបាយ (ដែលអង្គជំនុំជម្រះហៅជាសាធារណៈថា "អត្ថិភាពនៃគោលនយោបាយ") និងតួនាទីរបស់ជនជាប់ចោទក្នុងការអនុវត្តគោលនយោបាយ[34]។

---

[33] អនុស្សរណៈ **E141** ទំព័រ ៣។

[34] ប្រតិចារឹកសវនាការ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/211.1** ទំព័រ ១០៣ បន្ទាត់ ៤-១៣ (ភាសាបារាំង)។

៣៧. ពីដំបូង សំណុំរឿងត្រូវបានបំបែក ដើម្បីអាចពិនិត្យលម្អិត ក្នុងវគ្គជំនុំជម្រះសេចក្ដីបន្តបន្ទាប់ទៀត លើតួនាទីរបស់ជនជាប់ចោទក្នុងការបង្កើត **និង** ការអនុវត្តគោលនយោបាយ<u>នីមួយៗ</u>ដែលមានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ឧបសម្ព័ន្ធនៃសេចក្ដីសម្រេចជាបន្តបន្ទាប់លើការបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ ជាភស្តុតាង។ តាមរយៈការប្រែក្រឡាស់របស់ខ្លួន អង្គជំនុំជម្រះបានកាត់ផ្តាច់ភាពសមហេតុផលនៃវគ្គជំនុំជម្រះបន្តបន្ទាប់ទៀត។

៣៨. អំណើះតទៅ នៅក្នុងវគ្គជំនុំជម្រះបន្តបន្ទាប់នីមួយៗ វាហាក់ដូចជាលែងសម្រាប់កំណត់គោលនយោបាយផ្សេងៗ និងកំណត់តួនាទីរបស់ជនជាប់ចោទក្នុងការបង្កើត និងអនុវត្តគោលនយោបាយនីមួយៗ ប៉ុន្តែវាហាក់ដូចជាសម្រាប់បែងចែកឲ្យដាច់រវាង៖ ១) តួនាទីរបស់ជនជាប់ចោទក្នុងការ<u>បង្កើត</u>គោលនយោបាយឧក្រិដ្ឋទាំងប្រាំបូកបញ្ចូលគ្នា (គឺតួនាទីនេះហើយដែលនឹងត្រូវលើកយកមកពិនិត្យពិចារណានៅក្នុងអំឡុងវគ្គជំនុំជម្រះទីមួយ) និង ២) តួនាទីរបស់ជនជាប់ចោទក្នុងការ<u>អនុវត្ត</u>គោលនយោបាយឧក្រិដ្ឋទាំងនេះ ដោយហេតុថាមានតែតួនាទីរបស់ជនជាប់ចោទទាក់ទងនឹងការជម្លៀសប្រជាជន និងការប្រព្រឹត្តទៅលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរទេ ដែលនឹងត្រូវយកពិភាក្សាដេញដោល នៅក្នុងវគ្គជំនុំជម្រះទីមួយ។

៣៩. ការប្រែក្រឡាស់របស់អង្គជំនុំជម្រះនេះមានមូលហេតុតែមួយគត់ គឺខ្លួនមានឆន្ទៈសម្រួលដល់ការបំពេញកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញា ក្នុងការបង្ហាញភស្តុតាងផ្ទុះបញ្ជាំងអំពីគោលបំណងនៃឧក្រិដ្ឋកម្មរួម និងការចូលរួមរបស់ជនជាប់ចោទក្នុងការអនុវត្តគោលបំណងនេះ។ ជាក់ស្តែង ទាក់ទងនឹងទម្រង់ទំនួលខុសត្រូវលើ "សហឧក្រិដ្ឋកម្មរួម" ដីកាបញ្ជូនរឿងទៅជំនុំជម្រះចែងថា៖

*"ផែនការរួមរបស់មេដឹកបក្សកម្ពុជាប្រជាធិបតេយ្យ គឺធ្វើឲ្យសម្រេចនូវបដិវត្តន៍សង្គមនិយមឆាប់រហ័សនៅកម្ពុជា តាម "ជំហានមហាលោតផ្លោះ" និងការពារប្រទេសប្រឆាំងទៅនឹងសត្រូវទាំងខាងក្នុង និងខាងក្រៅ តាមគ្រប់មធ្យោបាយចាំបាច់។ ផែនការរួមនេះពុំមែនមានលក្ខណៈឧក្រិដ្ឋទាំងស្រុងនោះទេ ប៉ុន្តែការធ្វើឲ្យសម្រេចផែនការរួមនេះ រួមមាន ជាការប្រព្រឹត្តនូវឧក្រិដ្ឋកម្ម ដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ឬក៏ជាការជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ។ អាស្រ័យហេតុនេះ "ដើម្បីសម្រេចបានផែនការរួមនេះ <u>មេដឹកបក្សកម្ពុជាទំនងជាបាន</u>**<u>កំណត់</u>** <u>និង</u> **<u>ដាក់ឲ្យអនុវត្ត</u>**<u>គោលនយោបាយទាំង៥</u> ហើយដែលការដាក់ឲ្យអនុវត្តនេះទំនងជាការប្រព្រឹត្តឧក្រិដ្ឋ*

*កម្ម ឬក៏បណ្តាលឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្ម*'[35]។

៤០. ទាំងដីកាស្តាពររបស់សហព្រះរាជអាជ្ញា ទាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ សុទ្ធតែបង្ហាញគោលនយោបាយឧក្រិដ្ឋទាំង៥ ដែលចោទប្រកាន់ ដូចជា "វត្ថុទាំងមូលមួយ" ដែលជា "គោលបំណងឧក្រិដ្ឋរួម"[36]។ ដូច្នេះ អំណើះតទៅ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទក្នុងការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម នឹងត្រូវកាត់សេចក្តី នៅក្នុងវគ្គជំនុំជម្រះសេចក្តីទីមួយ ដើម្បីអាចប្រមូលផ្តុំនូវឧក្រិដ្ឋទាំងអស់ដែលមានកំណត់នៅក្នុងដីកាដំណោះស្រាយ។ ការប្រែក្រឡាស់ចុងក្រោយរបស់អង្គជំនុំជម្រះចំពោះសហឧក្រិដ្ឋកម្មរួម គឺស្មើនឹងការដាក់ឲ្យជនជាប់ចោទទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងអស់ដែលកើតចេញពីគោលនយោបាយទាំងអស់ ក្រោមទម្រង់ទទួលខុសត្រូវតែមួយ ដែលត្រូវកាត់សេចក្តីនៅក្នុងការជំនុំជម្រះក្តីវគ្គទី១ ៖ ការចូលរួមក្នុងសហឧក្រិដ្ឋរួម ដែលគោលបំណងគឺសម្រេចឲ្យបាននូវបដិវត្តសង្គមនិយមមួយដ៏ឆាប់រហ័សនៅកម្ពុជា។

៤១. ដោយហេតុថាការជំនុំជម្រះវគ្គទីមួយត្រូវបានបង្កើតឡើងក្នុងទស្សនទាននេះហើយ ដូច្នេះ ភារកិច្ចរបស់សហព្រះរាជអាជ្ញាគឺគ្រាន់តែបង្ហាញ៖

១) អត្ថិភាពនៃគោលបំណងរួមយ៉ាងស្រពេចស្រពិលនៃគោលនយោបាយឧក្រិដ្ឋទាំង៥ ដែលត្រូវបានចោទប្រកាន់ និង

២) ជ្រើសរើសយកផ្លូវងាយស្រួលពេកដែលអាចឲ្យសហព្រះរាជអាជ្ញាបង្ហាញ ដោយផ្អែកលើមូលដ្ឋានអំពើគ្រប់យ៉ាងនៃការចូលរួមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អំពីទំនួលខុសត្រូវរបស់ ជនជាប់ចោទ ចំពោះឧក្រិដ្ឋកម្មទាំងអស់ដែលកើតចេញពីគោលនយោបាយទាំង៥។ ក្រុមមេធាវីលោក ខៀវ សំផន បានព្យាយាមធ្វើការបង្ហាញអំពីអន្ទាក់នៃស្ថានភាពនេះ ដែលនឹងធ្វើឲ្យសហព្រះរាជ្ញារួចផុតពីបន្ទុកក្នុងការបង្ហាញភស្តុតាងនៃការចូលរួមដ៏សកម្មរបស់ជនជាប់ចោទក្នុងការកំណត់ **និង** ដាក់ឲ្យអនុវត្តរាល់គោលនយោបាយឧក្រិដ្ឋនីមួយៗ ដែលត្រូវបានចោទប្រកាន់[37]។

---

[35] ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ **D427** កថាខណ្ឌ ១៥២៤។

[36] ដីកាសន្និដ្ឋាស្តាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០ ឯកសារ **D390** កថាខណ្ឌ ១២៩៩ ដល់ ១៣១០ និងកថាខណ្ឌ ១៥៩៧ ដល់ ១៦០០។

[37] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន ពាក់ព័ន្ធនឹងច្បាប់ជាធរមាន ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ

៤២. លោក ខៀវ សំផន មិនដែលជំទាស់នឹងការបំបែកដំណើរការនីតិវិធីទេ ដរាបណាសេចក្ដីសម្រេច របស់អង្គជំនុំជម្រះបង្ហាញយ៉ាងច្បាស់ថាកម្មវត្ថុនៃការជំនុំជម្រះវគ្គទីមួយនេះ គឺផ្ដោតទៅលើការ ពិនិត្យពិចារណាយ៉ាងល្អិតល្អន់លើការចូលរួមរបស់លោក ខៀវ សំផន ក្នុងការកំណត់ **និង** ការ ដាក់ឱ្យអនុវត្តៈ ១) គោលនយោបាយនៃការជម្លៀសប្រជាជនចេញពីក្រុង និង ២) គោល នយោបាយទាក់ទងនឹងការប្រព្រឹត្តលើអតីតមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ។ ក្នុងលក្ខខណ្ឌនេះ ដីកា បំបែកដំណើរការនីតិវិធីប្រហែលជាអាចឱ្យយើងធ្វើការពិនិត្យពិចារណាច្បាស់លាស់ អំពីទម្រង់ នៃទំនួលខុសត្រូវ "ពីបទចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម" ដោយធៀបតែទៅនឹងគោលនយោបាយ ដែលជាកម្មវត្ថុនៃការជំនុំជម្រះសេចក្ដីវគ្គទី ១ នេះតែប៉ុណ្ណោះ[38]។

៤៣. ក៏ប៉ុន្តែ វាមានផលវិបាកធ្ងន់ធ្ងរបំផុតដែលជាមូលហេតុនៃសំណើរនេះ។ ដោយហេតុថា សេចក្ដី បកស្រាយថ្មីដែលអង្គជំនុំជម្រះបានធ្វើលើដីកាបំបែកដំណើរការនីតិវិធីរបស់ខ្លួន ធ្វើឱ្យលោក ខៀវ សំផន បាត់បង់សមត្ថភាពការពារខ្លួនដោយប្រសិទ្ធភាពទាំងស្រុង[39] ពីព្រោះថា នៅពេលដែលធ្វើ ការវិនិច្ឆ័យដាច់ដោយឡែកពីគ្នា លើការចូលរួមរបស់ជនជាប់ចោទ ក្នុងការកំណត់គោលនយោ- បាយទាំង៥ និងការដាក់ឱ្យអនុវត្តគោលនយោបាយទាំង៥នេះ អង្គជំនុំជម្រះបានព្យាយាមបង្កើតវគ្គ

---

២០១៣ ឯកសារ E163/5/9 កថាខណ្ឌ ៥៧។

[38] [អង្គជំនុំជម្រះសាលាដំបូង] បានបញ្ជាក់យ៉ាងច្បាស់នៅក្នុងសេចក្ដីសម្រេច E124/7 របស់ខ្លួន ត្រង់កថាខណ្ឌ ១០ ថា ហេតុផលមួយក្នុងចំណោមហេតុផលទាំងឡាយដែលនាំឱ្យអង្គជំនុំជម្រះចេញដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី គឺដើម្បី "ធានាថា បញ្ហានានា និងការចោទប្រកាន់ជាសារវន្តប្រឆាំងនឹងជនជាប់ចោទទាំងអស់ នឹងត្រូវពិនិត្យយ៉ាងលម្អិត នៅក្នុងការជំនុំជម្រះដំណាក់កាលដំបូង"។ ក្នុងចំណោមហេតុផលទាំងនេះ អង្គជំនុំជម្រះក៏បានលើកឡើងផងដែរអំពីឆន្ទៈរបស់ខ្លួនក្នុងការ "ផ្ដល់នូវមូលដ្ឋានសម្រាប់ការពិនិត្យលម្អិតលើបទចោទ និងការចោទប្រកាន់នានដែលនៅសេសសល់ប្រឆាំងនឹងជនជាប់ចោទ នៅក្នុងការជំនុំជម្រះលើកក្រោយ"។ ដូចគ្នាដែរ ការប្រកាសពីចេតនានេះធ្វើឡើងក្នុងន័យធ្វើការពិនិត្យលម្អិត និងច្បាស់លាស់លើបទចោទដែលទទួលយក ប្រឆាំងនឹងជនជាប់ចោទ ហើយគ្មានអ្វីដែលអាចឱ្យក្រុមមេធាវីការពារក្ដីប្រមើលមើលពីលទ្ធភាពដែលថា អង្គជំនុំជម្រះនឹងធ្វើការពិនិត្យលើទំនួលខុសត្រូវរបស់ជនជាប់ចោទ ពាក់ព័ន្ធនឹងគោលនយោបាយទាំងប្រាំ ដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ នោះទេ។

[39] ប្រតិចារឹកសវនាការ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ E1/211.1 ទំព័រ ១០៣ បន្ទាត់ ៤ ដល់ ១៣ (ភាសាបារាំង), ប្រតិចារឹកសវនាការ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ E1/212.1 ទំព័រ ១០ បន្ទាត់ ២០ ដល់ទំព័រ ១១ បន្ទាត់ ៥ (ភាសាបារាំង)។

ជំនុំជម្រះបន្តបន្ទាប់គ្នាដែលគ្មានភាពសមហេតុផល និងដែលនឹងធ្វើដំណើរការកាត់សេចក្តី ដោយផ្អែកលើទម្រង់ទំនួលខុសត្រូវមួយដែលពុំត្រូវបានយកមកពិចារណាឱ្យបានស៊ីជម្រៅ ហើយដែលនឹងត្រូវយកមកប្រើជាគោល នៅក្នុងវគ្គជំនុំជម្រះជាច្រើនបន្តបន្ទាប់ទៀត។ អាស្រ័យហេតុដូចនេះ មេធាវីការពារក្តីលោក ខៀវ សំផន នឹងមិនអាចធ្វើអ្វីដែលគេហាមមិនឱ្យធ្វើបច្ចុប្បន្ននេះ នៅថ្ងៃអនាគត។ ដូច្នេះ វាជាការដាក់កំហិតពីរជាន់។

## ២) <u>ទម្រង់ទំនួលខុសត្រូវមួយយដែលពុំត្រូវបានពិចារណាឱ្យស៊ីជម្រៅ និងដែលគ្របដណ្តប់លើវគ្គជំនុំជម្រះជាច្រើន</u>

៤៤. យើងទើបនឹងឃើញស្រាប់ហើយថាអង្គជំនុំជម្រះ បានធ្វើសេចក្តីសម្រេចដ៏ធ្ងន់ធ្ងរបំផុតមួយ ដោយបានកំណត់វិសាលភាពសំណុំរឿង ០០២/០១ នេះ មកត្រឹមតែការពិចារណាលើឧក្រិដ្ឋកម្មដែលកើតចេញពីគោលនយោបាយដ៏តិចតួច ហើយថែមទាំងចចេសវិនិច្ឆ័យ ក្នុងពេលជំនុំជម្រះវគ្គទីមួយនេះ ទៅលើទម្រង់ទំនួលខុសត្រូវស្រពេចស្រពិលមួយ ដើម្បីអាចពិចារណាក្តោបលើឧដ្ឋកម្មផ្សេងៗទៀតទាំងអស់ដែលមានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងអឡុងពេលជំនុំជម្រះវគ្គក្រោយទៀត។

៤៥. ម៉្យាង វិធីសាស្ត្រនេះបានន័យថាមិនទាន់ទាំងចេញសាក្រមផង អង្គជំនុំជម្រះបានពិចារណាកំណត់ទ្រឹស្តីនៃសហឧក្រិដ្ឋកម្មរួម ក្នុងទស្សនទានមួយងាយស្រួលហួសហេតុពេក ពីព្រោះថានៅពេលដែលបង្ហាញគោលនយោបាយទាំង៥ ថាជាវត្ថុតែមួយនៃ "បំណងឧក្រិដ្ឋ" ការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ក្លាយមកត្រឹមតែជាការចូលរួមរបស់ជនជាប់ចោទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[40]។ ការអនុវត្តទ្រឹស្តីបែបនេះ ធ្វើឱ្យការចូលរួមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ស្មើនឹងពិរុទ្ធភាពរបស់ជនជាប់ចោទជាស្រេច ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ១៩៧៩ ដោយមិនអាស្រ័យទៅតាមតួនាទី មុខងារ និងសកម្មភាពផ្ទាល់របស់ជនជាប់ចោទម្នាក់ៗ នៅក្នុងរបបនោះ។ ដូច្នេះ យើងប្រាសចាស យ៉ាងគ្រោះថ្នាក់ ពីគោលការណ៍ទំនួលខុសថ្នាក់ជាបុគ្គល។

---

[40] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន ពាក់ព័ន្ធនឹងច្បាប់ជាធរមាន ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ ឯកសារ **E163/5/9** កថាខណ្ឌ ៤៨។

៤៦. ម្យ៉ាងទៀត តាមលក្ខណៈគួរឲ្យព្រួយបារម្ភលើសនេះទៀត របៀបថ្មីដែលអង្គជំនុំជម្រះបកស្រាយ ដីកាបំបែកដំណើរការនីតិវិធីរបស់ខ្លួនបានន័យថាក្រោយពីបញ្ចប់ការជំនុំជម្រះវគ្គទី១ ចៅក្រមនឹង សម្រេចនៅក្នុងសាលក្រមរបស់ខ្លួន អំពីតួនាទីរបស់ជនជាប់ចោទ នៅក្នុង "ការបង្កើត" គោល នយោបាយទាំងអស់ ប៉ុន្តែនឹងសម្រេចលើ "ការដាក់ឲ្យអនុវត្ត" គោលនយោបាយមួយចំនួនតែ ប៉ុណ្ណោះ។ លើសពីនេះទៀត ដូចដែលតុលាការកំពូលបានប្រកាស អង្គជំនុំជម្រះទីពីរដែលសមាស ភាពចៅក្រមថ្មី នឹងសម្រេចលើតួនាទីរបស់ជនជាប់ចោទ ចំពោះ "ការដាក់ឲ្យអនុវត្ត" គោល នយោបាយទាំង ៣ ដែលនៅសេសសល់។ ការអង្គុនដំណើរការនីតិវិធីបែបនេះ គ្មានន័យទេទាំង ផ្នែកទ្រឹស្តី និងការអនុវត្ត។

៤៧. ជាក់ស្តែង ក្នុងបរិបទនៃការពិចារណាអំពីទំនួលខុសត្រូវរបស់ជនជាប់ចោទចំពោះការចូលរួមក្នុង សហឧក្រិដ្ឋកម្មរួម ការបែងចែកឲ្យដាច់ពីគ្នារវាង "អត្ថិភាព" នៃគោលនយោបាយ និង "ការដាក់ ឲ្យអនុវត្ត" គោលនយោបាយទាំងនេះ គឺមានលក្ខណៈបំភាន្ត។ របៀបដែលសវនាការស្តីអំពីការ បង្ហាញឯកសារគន្លឹះទាក់ទងនឹងសហឧក្រិដ្ឋកម្មបានប្រព្រឹត្តទៅ បានឆ្លុះបញ្ចាំងអំពីការបំភាន្តនេះ ពីព្រោះថាសហព្រះរាជអាជ្ញាបានប្រើមិនចេះចប់មិនចេះហើយនូវឯកសារនិយាយអំពី "ការដាក់ឲ្យ អនុវត្ត" គោលនយោបាយផ្សេងៗទៀត ដើម្បីព្យាយាមបង្ហាញថា៖ ១) មជ្ឈិមបានអនុវត្តគោល នយោបាយទាំងនេះ និង២)ជនជាប់ចោទបានដឹងឮអំពីអត្ថិភាពនៃគោលនយោបាយទាំងនេះ។ ការ លំបាកដែលបង្កដោយវិធានថ្មីនេះ និងការជំទាស់ជាច្រើនដែលវិធាននេះបានបង្កឡើង ក្នុងអំឡុង ពេលសវនាការទាំងនេះ បង្ហាញអំពីភាពគ្មានន័យនៃការបែងចែកបែបនេះ។

៤៨. អាស្រ័យហេតុដូចនេះ ភាពខុសគ្នាមិនពិតដែលលោកចៅក្រម ឡាវែញ LAVERGNE បានពន្យល់ រវាង "ការដាក់ឲ្យអនុវត្ត នៅថ្នាក់មជ្ឈិម" និង "ការដាក់ឲ្យអនុវត្តនៅមូលដ្ឋាន" ឆ្លុះបញ្ចាំងយ៉ាង ច្បាស់អំពីលក្ខណៈបោកបញ្ឆោតនៃការបកស្រាយថ្មីដែលលោកស្រីចៅក្រម CARTWRIGHT បានធ្វើមុនហ្នឹងមួយថ្ងៃ៖

*"[...] អង្គជំនុំជម្រះយល់ឃើញថាឯកសារដែលការិយាល័យសហព្រះរាជអាជ្ញាបង្ហាញក្នុងពេលនេះ ទាក់ទងនឹងសេចក្តីណែនាំ ដែលត្រូវដាក់ឲ្យអនុវត្តក្នុងក្របខណ្ឌនៃគោលនយោបាយស្តីពី សហករណ៍ និងសេចក្តីណែនាំដែលត្រូវបានបង្កើតឡើងនៅថ្នាក់មជ្ឈិម។ ដូច្នេះ វាមិនមែនជាការដាក់ឲ្យអនុវត្ត នៅមូលដ្ឋានទេ ហើយមិនត្រូវយកការដាក់ឲ្យអនុវត្តនៅមូលដ្ឋាននេះមកនិយាយក្នុងការបង្ហាញ*

*ឯកសារគន្លឹះ នៅក្នុងក្របខណ្ឌនៃការជំនុំជម្រះសេចក្តីនេះទេ។ អាស្រ័យហេតុដូចនេះ ការជំទាស់របស់ក្រុមមេធាវីលោក ខៀវ សំផន ត្រូវបដិសេធចោល។[41]"*

៤៩. បើសិនជាមានតែការដាក់ឱ្យអនុវត្តគោលនយោបាយ "នៅមូលដ្ឋាន" ទេ ដែលចេញក្រៅវិសាលភាពនៃការជំនុំជម្រះវគ្គទីមួយនេះ ប៉ុន្តែការដាក់ឱ្យអនុវត្តគោលនយោបាយទាំងនេះ "នៅថ្នាក់មជ្ឈិម" ស្ថិតនៅក្នុងវិសាលភាពនោះ វាបានន័យថាអង្គជំនុំជម្រះមិនបានបែងចែកឱ្យដាច់ពីគ្នាទាល់តែសោះរវាង"អត្ថិភាព" នៃគោលនយោបាយ និង "ការដាក់ឱ្យអនុវត្ត" គោលនយោបាយទាំងនេះ។ កាន់តែអាក្រក់ជាងនេះទៅទៀត វាបានន័យថាអង្គជំនុំជម្រះមិនទាំងបានញែកឱ្យដាច់ពីគ្នារវាងតួនាទីរបស់ជនជាប់ចោទ "ក្នុងការបង្កើតគោលនយោបាយ" និង "ក្នុងការដាក់ឱ្យអនុវត្ត" ផងទេ។ នៅទីបញ្ចប់ វាគ្រាន់តែបានន័យថា នៅក្នុងក្របខណ្ឌនៃការជំនុំជម្រះវគ្គទី១នេះ អង្គជំនុំជម្រះពិតជាចង់បង្ហាញថាជនជាប់ចោទពិតជាមានទំនួលខុសត្រូវចំពោះគោលនយោបាយទាំង៥នេះ។

៥០. ជាផលវិបាក បើតុលាការកំពូលមិនបង្គាប់ឱ្យបញ្ឈប់កិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនេះភ្លាមទេនោះ យើងមើលមិនឃើញថា តើចៅក្រមថ្មីអាចពិចារណាអំពីទំនួលខុសត្រូវរបស់ជនជាប់ចោទចំពោះឧក្រិដ្ឋកម្មដែលនឹងជាកម្មវត្ថុនៃការជំនុំជម្រះវគ្គទី២ យ៉ាងដូចម្តេចនោះទេ ពីព្រោះថាទំនួលខុសត្រូវរបស់ជនជាប់ចោទចំពោះគោលនយោបាយដែលបង្កឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ នឹងត្រូវបានកាត់សេចក្តីពិចារណាដោយអង្គជំនុំជម្រះយើងនេះ នៅក្នុងអំឡុងពេលជំនុំជម្រះវគ្គទី១រួចស្រេចបាត់ទៅហើយ ដូចដែលបានជម្រាបជូនស្រាប់ហើយ មេធាវីការពារក្តីស្ថិតនៅក្នុងស្ថានភាពមួយ ដែលខ្លួនមិនអាចធ្វើក្នុងពេលបច្ចុប្បន្ននូវអ្វីដែលគេហាមឃាត់មិនខ្លួនធ្វើ នៅថ្ងៃអនាគត។ មេធាវីការពារក្តីត្រូវបានគេបំបិទមាត់។

៥១. ដូច្នេះ ដោយហេតុថាអង្គជំនុំជម្រះបានចេញក្រៅក្របខណ្ឌដែលខ្លួនឯងផ្ទាល់បានកំណត់ ដោយហេតុថាអង្គជំនុំជម្រះធ្វើជាមិនដឹងមិនឮអំពីភាពសមហេតុផលតាមផ្លូវច្បាប់ជាមូលដ្ឋាន តុលាការកំពូលមានដំណោះស្រាយតែមួយគត់ ហើយការគោរពសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទតម្រូវឱ្យបញ្ឈប់កិច្ចដំណើរការនីតិវិធីបច្ចុប្បន្នភ្លាមៗតែម្តង។

[41] ប្រតិចារឹកសវនាការ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/212.1** ទំព័រ ១០ បន្ទាត់ ២០ ដល់ទំព័រ ១១ បន្ទាត់ ៥ (ភាសាបារាំង)។

## គ. អសុវត្ថិភាពគតិយុត និងការរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោក ខៀវ សំផន

### ១) គោលជំហររបស់លោក ខៀវ សំផន ចំពោះការបំបែកបទចោទ

៥២. តាំងពីពេលចាប់ផ្តើមការជំនុំជម្រះសេចក្តីវគ្គទី១នេះមក គោលជំហរមេធាវីការពារក្តីលោក ខៀវ សំផន ចំពោះដីកាបំបែកកិច្ចដំណើរការនីតិវិធី នៅតែមានភាពស៊ីសង្វាក់គ្នាដដែល ដោយហេតុថា ជាគោលការណ៍ ខ្លួនមិនដែលជំទាស់នឹងការបំបែកបទចោទនោះទេ។ សារណាទាំងអស់របស់ខ្លួន ទាក់ទងនឹងបញ្ហានេះត្រូវគ្នានឹងគោលការណ៍នេះ និងឆ្លុះបញ្ចាំងអំពីសុច្ចរិតភាពរបស់ខ្លួន[42]។

៥៣. មេធាវីការពារក្តីមិនបានជំទាស់នឹងការបំបែកបទចោទទេ ដរាបណាការបំបែកនេះមិនប៉ះពាល់ដល់ គោលការណ៍នៃការអាចគ្រោងទុកជាមុនបានតាមផ្លូវច្បាប់ និងដល់គោលការណ៍ជំនុំជម្រះក្តីប្រកប ដោយយុត្តិធម៌។ គោលការណ៍ទាំងនេះតម្រូវឱ្យអនុវត្តយ៉ាងច្បាស់លាស់តាមការអង្គនដីកាបញ្ជូន រឿងទៅជំនុំជម្រះដែលអង្គជំនុំជម្រះបានធ្វើទៅក្នុងឧបសម្ព័ន្ធរបស់ខ្លួនជាបន្តបន្ទាប់។ គោលការណ៍ ទាំងនេះតម្រូវឱ្យមានការបង្កើតបទបញ្ហាតឹងរ៉ឹងមួយសម្រាប់ការដាក់ឱ្យពិភាក្សាដេញដោលតែធាតុ

---

[42] ជំហររបស់មេធាវីការពារក្តីលោក ខៀវ សំផន មានភាពស៊ីសង្វាក់គ្នាជានិច្ច ទៅនឹងការបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុង សំណុំរឿងនេះ។ សូមមើលប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **E147.1** ទំព័រ ៣ បន្ទាត់ ១៤ ដល់ទំព័រ ៤ បន្ទាត់ ២៣ (ភាសាបារាំង), មតិគាំទ្រសំណើរបស់លោក អៀង សារី E221 និងស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងឱ្យ បង្គាប់ដល់សហព្រះរាជអាជ្ញាធ្វើការកែតម្រូវបញ្ជីសាក្សីកម្មជាលាយលក្ខណ៍អក្សរ ដែលសហព្រះរាជអាជ្ញាមានបំណងដាក់ បញ្ចូលក្នុងការពិភាក្សាដេញដោល ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ ឯកសារ **E223** កថាខណ្ឌ ១១ និងកថាខណ្ឌបន្តបន្ទាប់, ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំ រឿង ០០២/០១ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារ E163/5/1/9 កថាខណ្ឌ ២៤-៤៣, សេចក្តីសន្និដ្ឋានបញ្ចប់ការ ពិភាក្សាដេញដោលរបស់លោក ខៀវ សំផន ពាក់ព័ន្ធនឹងច្បាប់ជាធរមាន ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ ឯកសារ **E163/5/9** កថាខណ្ឌ ៣៣-៥៧, សេចក្តីជំទាស់របស់លោក ខៀវ សំផន ទៅនឹងការដាក់បញ្ចូលក្នុងកិច្ចពិភាក្សានូវសក្ខីកម្មជាលាយលក្ខណ៍ អក្សរមួយចំនួន ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **E208/5** កថាខណ្ឌ ២៨-៤១, ប្រតិចារឹកសវនាការ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/213.1** ទំព័រ ៤៨ បន្ទាត់ ២៣ ដល់ទំព័រ ៥៣ បន្ទាត់ ៥ (ភាសាបារាំង)។

ផ្សំភស្តុតាងណាដែលមានជាប់ទាក់ទងនឹងអង្គហេតុដែលជាកម្មវត្ថុនៃការជំនុំជម្រះវគ្គទី១ និងតម្រូវឲ្យមានផងដែរនូវឱកាសពិតប្រាកដមួយដើម្បីពិភាក្សាដេញដោលអំពីធាតុផ្សំភស្តុតាងទាំងនេះ។ នៅទីបញ្ចប់ គោលការណ៍ទាំងនេះតម្រូវឲ្យសេចក្ដីណែនាំទាក់ទងនឹងដែនកំណត់នៃការសួរសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី មានតម្លាភាព មានភាពស៊ីសង្វាក់គ្នា និងមានភាពយុត្តិធម៌។ ប៉ុន្តែ អ្វីដែលបានធ្វើកន្លងមកមិនដូចនឹងការលើកឡើងខាងលើនេះទេ។

## ១.១. អសមត្ថភាពរបស់អង្គជំនុំជម្រះក្នុងការកំណត់ក្របខណ្ឌគតិយុត្តច្បាស់លាស់មួយ ដើម្បីគ្រប់គ្រងលើភស្តុតាងជាឯកសារ ក្នុងបរិបទនៃការជំនុំជម្រះក្ដីដែលត្រូវបានបំបែកជាវគ្គតូចៗ

៥៤. អង្គជំនុំជម្រះមិនដែលមានសមត្ថភាពក្នុងការប្រកាន់យកគោលជំហរច្បាស់លាស់ណាមួយទេ ចំពោះសំនួរដែលសួរថាតើឯកសារដែលនៅក្រៅអង្គហេតុជាកម្មវត្ថុនៃសំណុំរឿង ០០២/០១ អាចទទួលយកបាន ឬក៏អត់ ស្របតាមលក្ខខណ្ឌតម្រូវនៃភាពពាក់ព័ន្ធ ដែលមានចែងនៅក្នុងវិធាន ៨៧-៣ នៃវិធានផ្ទៃក្នុង។

៥៥. អាស្រ័យហេតុដូចនេះហើយបានជា នៅថ្ងៃទី២៥ តុលា ២០១១ ភាគីទាំងអស់ត្រូវបានស្នើឲ្យធ្វើការជំទាស់ឲ្យបានមុនថ្ងៃទី ៥ មករា ២០១២ លើការដាក់ឯកសារឲ្យពិភាក្សាដេញដោល ដែលស្នើឡើងដោយសហព្រះរាជអាជ្ញា នៅក្នុងឧបសម្ព័ន្ធ ១ ដល់ ១១[43]។ ក្នុងក្របខណ្ឌនេះ ក្រុមមេធាវីការពារក្ដីទាំងអស់បានធ្វើការជំទាស់សុំឲ្យដកចេញពីការពិភាក្សាដេញដោល នូវឯកសារពាក់ព័ន្ធនឹងគោលនយោបាយឧក្រិដ្ឋ ដែលគ្មានទំនាក់ទំនងនឹងសំណុំរឿង ០០២/០១[44]។

---

[43] បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5 ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ ឯកសារ **E131/1** ("អនុស្សរណៈ **E131/1**") ទំព័រ ២។

[44] ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **E147.1** ទំព័រ ៣ បន្ទាត់ ១៤ ដល់ទំព័រ ៤ បន្ទាត់ ២៣ (ភាសាបារាំង)។ សូមមើលផងដែរ៖ *ការជំទាស់ ការកត់សម្គាល់ និងការជូនដំណឹងទាក់ទងនឹងឯកសារផ្សេងៗដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ **E131/1/9** កថាខណ្ឌ ១០ និង ២០, *ការជំទាស់ទៅនឹងឯកសារ និងសារណាបន្ថែមដោយអនុលោមតាមវិធាន ៩២* ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២ ឯកសារ **E131/1/12** កថាខណ្ឌ ១, *ការជំទាស់របស់លោក អៀង សារី ចំពោះការទទួលយកឯកសារមួយចំនួនពីការិយាល័យសហព្រះរាជអាជ្ញាសម្រាប់សវនាការបូនវគ្គដំបូង* ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២ ឯកសារ **E131/1/10** (និងឧបសម្ព័ន្ធពាក់ព័ន្ធ)។

៥៦. ក៏ប៉ុន្តែ អង្គជំនុំជម្រះបានបដិសេធការជំទាស់ទាំងអស់នោះ ដោយផ្តល់សំអាងហេតុថាវាជាការជំទាស់ *"ខ្វះភាពជាក់លាក់"*[45]។ ក្នុងពេលនេះ យើងយល់ថា ដោយបានគេចវេះមិនព្រមពិចារណា អង្គជំនុំជម្រះបានគេចវេះក្នុងការសម្រេចលើសំនួរដែលសួរថាតើសហព្រះរាជអាជ្ញាមានសិទ្ធិស្នើដាក់ឲ្យពិភាក្សាដេញដោល នូវឯកសារពាក់ព័ន្ធនឹងគោលនយោបាយ ដែលមិនមែនជាកម្មវត្ថុនៃសំណុំរឿង ០០២/០១ ដែរឬទេ? បើសម្រេចថាមានសិទ្ធិ យើងខ្ញុំសុំឲ្យអង្គជំនុំជម្រះបញ្ជាក់ថាតើខ្លួនមានចំណាត់ការបែបណាចំពោះឯកសារទាំងនេះ។

៥៧. បន្ទាប់មកទៀត អង្គជំនុំជម្រះបានប្រកាន់យកគោលជំហរមិនច្បាស់លាស់ដូចគ្នានេះដែរ ចំពោះកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរដែលសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីចង់ឲ្យទទួលយកជំនួសសក្ខីកម្មផ្ទាល់។ មេធាវីការពារក្តីលោក ខៀវ សំផន បានសុំឲ្យអង្គជំនុំជម្រះបង្គាប់ឲ្យសហព្រះរាជអាជ្ញាកែប្រែបញ្ជីកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់ខ្លួន ដោយហេតុថាចម្លើយនេះភាគច្រើននៅក្រៅវិសាលភាពនៃការជំនុំជម្រះវគ្គទី១។ នៅក្នុងសំណើរបស់ខ្លួន មេធាវីការពារក្តី យោងទៅសេចក្តីសម្រេចចុះថ្ងៃទី ២០ មិថុនា ២០១២ ដែលនៅក្នុងសេចក្តីសម្រេចនេះអង្គជំនុំជម្រះបានបង្គាប់ឲ្យដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាដូចនេះ៖ *"ទាក់ទងនឹង [...] បណ្តឹងទាំងឡាយដែលមិនពាក់ព័ន្ធនឹងកម្មវត្ថុនៃសវនាការ នៃសំណុំរឿង ០០២/០១ អាចខកខានថែមទៀតក្នុងការបំពេញលក្ខណវិនិច្ឆ័យ នៃភាពពាក់ព័ន្ធអនុលោមតាមវិធាន៨៧ ៣) ក) នៃវិធានផ្ទៃក្នុង"*[46]។ សេចក្តីសម្រេចនេះបានធ្វើឲ្យគេជឿថាអង្គជំនុំជម្រះនឹងមិនទទួលយកធាតុផ្សំភស្តុតាងដែលមិនពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ នោះទេ។

---

[45] សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងឧសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ ឯកសារ **E185** ("សេចក្តីសម្រេច **E185**") កថាខណ្ឌ ២៣, សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅក្នុងឧសម្ព័ន្ធ A6-A11 និង A14-A20 របស់សហព្រះរាជអាជ្ញា និងឯកសារដែលបានស្នើឡើងដោយភាគីផ្សេងទៀត ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារ **E185/1** ("សេចក្តីសម្រេច **E185/1**") កថាខណ្ឌ ១២។

[46] សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារ **E96/7** កថាខណ្ឌ ២៩។

៥៨. ក៏ប៉ុន្តែ ផ្ទុយពីការរំពឹងរង់ចាំទាំងស្រុង អង្គជំនុំជម្រះនឹងសម្រេចថា... នឹងមិនសម្រេចលើអ្វីទាំងអស់។ ជាក់ស្តែង អង្គជំនុំជម្រះបានត្រឹមតែដាក់កាលកំណត់មួយឱ្យសហព្រះរាជអាជ្ញា ចំពោះការបកប្រែឯកសារនានាដែលមិនទាន់បានបកប្រែជាបីភាសា[47]។ ដូច្នេះ អង្គជំនុំជម្រះមិនបានសម្រេចឱ្យច្បាស់លាស់អំពីបញ្ហាភាពពាក់ព័ន្ធនៃឯកសារទាក់ទងនឹងគោលនយោបាយដែលមិនមែនជាកម្មវត្ថុនៃសវនាការនៃសំណុំរឿង ០០២/០១។ ភាពមិនច្បាស់លាស់ដ៏ច្បាស់ក្រឡែតនេះស្តែងឡើងតាមរយៈការដែលអង្គជំនុំជម្រះបានលើកឡើងដោយកុហក់ នៅក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីទីពីរ ដែលនៅក្នុងនោះ អង្គជំនុំជម្រះបានអះអាងថា "*វាច្បាស់ណាស់ថាចាប់តាំងពីដំបូងមកអង្គជំនុំជម្រះបានសម្រេចថាភាគីទាំងអស់អាចបង្ហាញភស្តុតាងទាក់ទងនឹង<u>តួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទទាក់ទងគោលនយោបាយ</u> ដែលត្រូវបានចោទប្រកាន់ នៅក្នុងដីកាដំណោះស្រាយ*"[48]។ អ្វីៗទាំងអស់ត្រូវបានបញ្ចប់ជាស្ថាពរ។ រីឯមេធាវីការពារក្តីត្រូវបានបំបិទមាត់។

៥៩. ដើម្បីគាំទ្រការអះអាងដោយកុហក់នេះ អង្គជំនុំជម្រះដក់ស្រង់កថាខណ្ឌនានានៃដីកាដំណោះស្រាយទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[49]។ អង្គជំនុំជម្រះក៏បានផ្តល់ហេតុផលផងដែរ ដោយលើកយកផ្នែកមួយនៃអនុស្សារណៈដ៏សាមញ្ញមួយដែលនៅក្នុងនោះអង្គជំនុំជម្រះបានអនុញ្ញាតឱ្យភាគីទាំងអស់អាចសួរអ្នកជំនាញ ហួសពីវិសាលភាពនៃសំណុំរឿង ០០២/០១ ពីព្រោះខ្លួនប្រកាសថា៖ "ព្យាយាមបញ្ចៀសការហៅ [អ្នកទាំងអស់នោះ] មកផ្តល់សក្ខីកម្ម លើសពី មួយដង"។ ក៏ប៉ុន្តែ នៅក្នុងអនុស្សារណៈនោះ ពុំមានអ្វីដែលបញ្ជាក់ថា ៖ "*អង្គជំនុំជម្រះបានសម្រេចថាភាគីទាំងអស់អាចបង្ហាញភស្តុតាងទាក់ទងនឹង<u>តួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទទាក់ទងគោលនយោបាយ</u>*" នោះទេ។ ផ្ទុយពីនេះស្រលះ អង្គជំនុំជម្រះក៏បាន

[47] សវនាការដេញដោលលើឯកសារនាពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់ប្រើប្រាស់នៅសវនាការ (ឯកសារ E208/4) និងសំណើរបស់មេធាវីការពារជនជាប់ចោទ ខៀង សំផន ស្នើសុំកែតម្រូវបញ្ជីភស្តុតាងគាំទ្រ (ឯកសារ E223) ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ ឯកសារ **E223/2** កថាខណ្ឌ ៩។

[48] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី **E284** កថាខណ្ឌ ១១៧។

[49] ដូចយោងខាងលើ។ សូមមើលកំណត់សម្គាល់ជើងទំព័រ ២១៥។

រំលឹកដល់ភាគីផងដែរថា "សំណួររបស់ភាគី [ត្រូវតែ] បន្តផ្តោតជាសំខាន់លើប្រធានបទពាក់ព័ន្ធការជំនុំជម្រះវគ្គទី១"។ អង្គជំនុំជម្រះក៏បានបន្ថែមផងដែរថា៖ *"សំណួរដែលនៅក្រៅវិសាលភាពនេះ [ត្រូវតែ] រឹតត្បិតមកត្រឹមផ្នែកដែលភាគីយល់ឃើញថា អ្នកផ្តល់សក្ខីកម្មនោះ [ជា] មនុស្សតែម្នាក់គត់ ដែលអាចផ្តល់ចម្លើយមួយចំនួនបាន"*[50]។ ដូច្នេះ អង្គជំនុំជម្រះលេងពាក្យ ដោយធ្វើឱ្យមានភាពមិនច្បាស់លាស់ ដើម្បីផ្តល់យុត្តិកម្មដល់ភាពអយុត្តិធម៌។

៦០. នៅពេលចេញ គ្មានការបកស្រាយសមហេតុផលណាមួយនៃអនុសារណៈនេះ ដែលអាចធ្វើឱ្យមេធាវីការពារក្តីគិតថាអង្គជំនុំជម្រះនឹងប្រើវានៅថ្ងៃណាមួយ នៅក្នុងដីកាសម្រេចបំបែកកិច្ចដំណើរនីតិវិធីទីពីរ ដើម្បីអះអាងថា៖ *"គ្មានអ្វីដែលរារាំងមិនឱ្យសហព្រះរាជអាជ្ញាជាច្រើនឱ្យអស់លទ្ធភាពដែលមាននៅចំពោះមុខអង្គជំនុំជម្រះ ទាក់ទងនឹង ស២១ ឡើយ ក្នុងកម្រិតដែលពាក់ព័ន្ធនឹងតួនាទីថ្នាក់ដឹកនាំ ឬរចនាសម្ព័ន្ធទំនាក់ទំនងការងារ នៅក្នុងកម្ពុជាប្រជាធិបតេយ្យ។[51]"*

## ១.២. <u>អសមត្ថភាពរបស់អង្គជំនុំជម្រះក្នុងការកំណត់ក្របខណ្ឌគតិយុត្តច្បាស់លាស់មួយ ដើម្បីគ្រប់គ្រងលើភស្តុតាងជាសក្ខីកម្ម ក្នុងការជំនុំជម្រះក្តីដែលត្រូវបានបំបែកជាវគ្គតូចៗ</u>

៦១. ដូចគ្នាដែរ អង្គជំនុំជម្រះ តែងតែនិយាយផ្ទុយនឹងខ្លួនឯង មិនចេះចប់មិនចេះហើយ អំពីវិសាលសក្ខីកម្មរបស់សាក្សី និងអ្នកជំនាញ។

៦២. ទាក់ទងវិសាលភាពនៃការសួរដេញដោលសាក្សី ដែលកំណត់ដោយអង្គជំនុំជម្រះ ក្នុងពេលសវនាការនៃសំណុំរឿង ០០២/០១ នេះ មេធាវីការពារក្តីលោក ខៀវ សំផន គាំទ្រទាំងស្រុងចំពោះការកត់សំគាល់របស់លោក នួន ជា នៅក្នុងបណ្តឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងនឹងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីទីពីរ[52]។

---

[50] សេចក្តីសម្រេចលើការចាត់តាំងអ្នកជំនាញ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ **E215** កថាខណ្ឌ ៤។

[51] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី **E284** កថាខណ្ឌ ១១៧។

[52] *បណ្តឹងសាទុក្ខភ្លាមៗជំទាស់នឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងសារណាតបចំពោះបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាជំទាស់នឹងសេចក្តីសម្រេចលើកទីពីរលើការបំបែកកិច្ចដំណើរការនីតិវិធី* ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **E284/4/1** កថាខណ្ឌ ១២-១៤ និងកថាខណ្ឌ ១៨-១៩។

៦៣. ទាក់ទងនឹងអ្នកជំនាញ មេធាវីការពារក្តីលោក ខៀវ សំផន បានជម្រាបជូនតុលាការកំពូលរួចហើយ អំពីការប្រែប្រួលឡាស់មិនចេះចប់មិនចេះហើយរបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះដែនកំណត់ដែលអនុញ្ញាតឲ្យចោទសំណួរ[53]។ ជាក់ស្តែង ការកម្រិតដ៏តឹងរឹងនៃចំនួនថ្ងៃសម្រាប់ចោទសំណួរ ដោយមាន *"ការលើកទឹកចិត្ត"* អំពីសំណាក់អង្គជំនុំជម្រះ ឲ្យសួរតែក្នុងវិសាលភាពនៃសំណុំរឿង ០២២/០១ គឺវាស្មើនឹងការបង្ខំឲ្យបង្រួញសំណួររបស់ខ្លួនមកត្រឹមតែក្នុងវិសាលភាពនៃសំណុំរឿង ០២២/០១[54]។

៦៤. ជាពិសេស មេធាវីការពារក្តីព្រួយបារម្ភ (រួចបាត់ទៅហើយ) អំពីសណ្ឋួរដូចតទៅនេះ ដែលសំណួរទាំងនេះមិនដែលត្រូវបានដោះស្រាយទាល់តែសោះ ហើយដែលផ្ទុយទៅវិញ វាជាប្រភពនៃការច្របូកច្របល់កាន់រីកធំឡើងៗ រាប់ខែមកហើយ៖

*"តើត្រូវត្រៀមសំណួរយ៉ាងដូចម្តេចបើពុំមានការកំណត់វិសាលភាពឲ្យបានច្បាស់លាស់ផងនោះ? តើយើងអាចជឿជាក់បានឬទេថានៅពេលណាដែលភាពពាក់ព័ន្ធនៃសំណួរនានាត្រូវបានកំណត់រួចហើយ តើយើងអាចចោទសំណួរទាំងអស់នេះបានដែរឬទេ? តើផ្នែកណាខ្លះនៃសក្ខីកម្មនឹងត្រូវចាត់ទុកថាមានភាពពាក់ព័ន្ធ ដោយចៅក្រម ហើយផ្នែកទាំងអស់នេះនឹងយកទៅប្រើយ៉ាងដូចម្តេចក្នុងករណីមានវគ្គជំនុំជម្រះសេចក្តីច្រើន? តើគួរប្រឹក្សាផ្នែកយុទ្ធសាស្ត្រដែលត្រូវប្រកាន់យកយ៉ាងដូចម្តេច?"*[55]។

៦៥. វាជាការត្រឹមត្រូវដែលមេធាវីការពារក្តីមានការព្រួយបារម្ភ។ ជាក់ស្តែង ឱកាសផ្តល់ឲ្យសួរអ្នកជំនាញទាំងអស់ លើវិសាលភាពនៃសំណុំរឿង ០០២ ទាំងមូល នៅតែលេចឡើង ក្នុងលក្ខណៈជាទ្រឹស្តីនៅឡើយ កាលពីថ្ងៃទីមួយនៃការផ្តល់សក្ខីកម្មរបស់លោកអ្នកជំនាញ Philip SHORT នៅថ្ងៃ

[53] បណ្តឹងសាទុក្ខភ្លាមៗរបស់មេធាវីការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចចេញតាមរយៈអ៊ីមែលរបស់លោកស្រី Susan Lamb នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ **E264/1/2/1** កថាខណ្ឌ ៣៨-៤៦។

[54] ដូចយោងខាងលើ កថាខណ្ឌ ៤៣។

[55] ដូចយោងខាងលើ កថាខណ្ឌ ៤៨។

ទី ០៦ ខែឧសភា ឆ្នាំ២០១៣ ក្នុងខណៈពេលដែលគាត់ឆ្លើយទៅនឹងសំណួររបស់ចៅក្រម គាត់បាន លើកឡើងអំពីការប្រល័យពូជសាសន៍ដោយធម្មជាតិ។ គាត់ក៏ត្រូវលោកស្រីចៅក្រម CARTWRIGHT កាត់សំដី៖

*"ខ្ញុំកាត់សំដីលោក។ "ពាក្យប្រល័យពូជសាសន៍" ជាពាក្យច្បាប់ ដែលគេប្រើច្រើន ប៉ុន្តែយើងមិន ពិចារណាអំពីអង្គហេតុទាំងអស់នេះទេ នៅក្នុងក្របខណ្ឌនៃវគ្គជំនុំជម្រះនេះ ដូច្នេះ សូមទុកប្រធានបទ នេះឲ្យចៅក្រមពិចារណាចុះ"*[56] ។

៦៦. សព្វថ្ងៃនេះ នៅពេលបិទសវនាការសម្រាប់បង្ហាញភស្តុតាងហើយ លោក ខៀវ សំផន លែងដឹងថា តើត្រូវទុកចិត្តលើ អ៊ីម៉ែលមួយណា? អនុស្សារណៈមួយណា? ឬក៏សេចក្តីសម្រេចមួយណា? ដើម្បី ឲ្យដឹងថាតើបទចោទមកលើរូបគាត់មានអ្វីខ្លះ នៅក្នុងក្របខណ្ឌនៃសំណុំរឿង ០០២/០១ នេះ? អ្វី ដែលប្រាកដនោះ គឺថានៅអំឡុងពេលជំនុំជម្រះនេះ មេធាវីរបស់គាត់គ្មានពេលណានឹងមានឱកាស និយាយឲ្យបានលម្អិត អំពីបញ្ហាទាក់ទងនឹងការអះអាងថា គាត់បានចូលរួមក្នុងការបង្កើតគោល នយោបាយទាំង៥ ដែលអង្គជំនុំជម្រះចង់ធ្វើសេចក្តីសម្រេច ចាប់ពីពេលនេះតទៅ។

៦៧. មេធាវីការពារក្តីលោក ខៀវ សំផន មិនដែលបានទទួលលទ្ធភាពក្នុងការការពារខ្លួនពីទម្រង់នៃទំនួល ខុសត្រូវណាមួយដែលត្រូវបានកំណត់ឡើង ដើម្បីគ្របដណ្តប់លើឧក្រិដ្ឋកម្មទាំងអស់ដែលត្រូវបាន ចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ។ ភស្តុតាងស្ថិតនៅត្រង់៖ គោលជំហរមិន ច្បាស់លាស់ដែលអង្គជំនុំជម្រះប្រកាន់យក អសមត្ថភាពរបស់អង្គជំនុំជម្រះក្នុងការបញ្ជាក់ឲ្យបាន ច្បាស់អំពីលក្ខណៈវិនិច្ឆ័យភាពពាក់ព័ន្ធ ដែលគ្រប់គ្រងលើភាពអាចទទួលយកបាននៃភស្តុតាងជា ឯកសារ នៅក្នុងការជំនុំជម្រះដែលបំបែកជាវគ្គតូចៗ និងការបង្អាប់ឲ្យកម្រិតវិសាលភាពនៃការ សួរដេញដោលអ្នកជំនាញ និងសាក្សី មកត្រឹមតែអង្គហេតុចោទប្រកាន់ក្នុងសំណុំរឿង ០០២/០១។

៦៨. នៅទីបញ្ចប់ លោក ខៀវ សំផន ត្រូវបានអង្គជំនុំជម្រះផ្តល់ឱកាសតែ ដើម្បីការពារខ្លួនប្រឆាំងនឹង ការចោទប្រកាន់ដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ តែប៉ុណ្ណោះ គឺបានន័យថាការ ចោទប្រកាន់លើទំនួលខុសត្រូវរបស់គាត់ ចំពោះ ១) គោលនយោបាយជម្លៀសប្រជាជនចេញពីទី-

---

[56] ប្រតិចារឹកសវនាការ ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **E1/189.1** ទំព័រ ៦៤ បន្ទាត់ ៧-១១ (ភាសាបារាំង) (យើងគូសបន្ទាត់ពីក្រោម)។

ក្រុង និង ២) ការប្រព្រឹត្តលើអតីតមេដឹកនាំនៃរបបសាធារណរដ្ឋខ្មែរ និងក្រុមគ្រួសាររបស់ពួកគេ។ ហើយត្រឹមប៉ុណ្ណឹង ឱកាសការពារខ្លួនពីការចោទប្រកាន់ដែលត្រូវបានកំណត់ក្នុងក្របខណ្ឌច្បាស់លាស់នៃការជំនុំជម្រះវគ្គមួយនេះ មានតែជាលក្ខណៈទ្រឹស្តីតែប៉ុណ្ណោះទេ ពីព្រោះវាច្បាស់ណាស់ថាចាប់តាំងពីដំបូង អង្គជំនុំជម្រះមិនដែលមានចេតនាដឹកនាំការជំនុំជម្រះសេចក្តីមួយ ប្រកបដោយយុត្តិធម៌ទេ។

## ii. __អវត្តមាននៃឆន្ទៈរបស់អង្គជំនុំជម្រះក្នុងការដឹកនាំកិច្ចសវនាការមួយប្រកបដោយយុត្តិធម៌__

៦៩. បច្ចុប្បន្ននេះ វាជាក់ច្បាស់ណាស់ថា អង្គជំនុំជម្រះពុំដែលមានបំណងផ្តល់ដល់លោក ខៀវ សំផន នូវមធ្យោបាយ ក្នុងការការពារខ្លួន និងក្នុងការធ្វើឱ្យចម្លើយរបស់ខ្លួនត្រូវបានស្តាប់ឡើយ។ ខ្លឹមសារដែលបង្ហាញជូនក្នុងផ្នែកនេះ គ្រាន់តែជាការដកស្រង់មួយចំនួនអំពីការរំលោភជាក់ស្តែងពីសំណាក់អង្គជំនុំជម្រះ លើកាតព្វកិច្ចរបស់ខ្លួនដែលតាមរយៈនោះ អង្គជំនុំជម្រះត្រូវធានាដល់លោក ខៀវ សំផន នូវ "សិទ្ធិដែលពុំមែនជាសិទ្ធិក្នុងលក្ខណៈជាទ្រឹស្តី ឬបែបស្រពិចស្រពិលនោះទេ ប៉ុន្តែជាសិទ្ធិជាក់ស្តែង និងច្បាស់លាស់"[57]។

## ក. __ការគ្មានឆន្ទៈក្នុងការផ្តល់នូវមធ្យោបាយដើម្បីត្រៀមរៀបចំការពារក្តីឱ្យមាន ប្រសិទ្ធភាព__

៧០. នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនកាលពី ខែ មិថុនា និង ខែ កក្កដា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានច្រានចោលសំណើសុំរបស់មេធាវីការពារក្តីលោក ខៀវ សំផន ក្នុងការស្នើសុំឱ្យមានការផ្តល់នូវថិរវេលា និងមធ្យោបាយចាំបាច់ដល់ការត្រៀមរៀបចំការតាំងសំណួររបស់ខ្លួន ព្រមទាំងការរៀបចំតាក់តែងសេចក្តីសន្និដ្ឋានការពារបញ្ចប់របស់ខ្លួន។

៧១. ពាក់ព័ន្ធនឹងការត្រៀមរៀបចំតាំងសំណួរទៅលើរូបលោក ខៀវ សំផន មេធាវីការពារក្តីបានស្នើសុំយ៉ាងសមហេតុសមផល និងត្រឹមត្រូវ៖

- ពីភាគីទាំងអស់ និងពីអង្គជំនុំជម្រះ នូវបញ្ជីសំណួររៀបតាមប្រធានបទដែលខ្លួនចង់សួរ។

[57] រឿងក្តី *Airey ទល់នឹងប្រទេសអៀរឡង់* តុលាការសិទ្ធិមនុស្សអឺរ៉ុប សំណើលេខ ៦២៨៩/៧៣ សាលដីកាលើអង្គសេចក្តី ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៧៩ កថាខណ្ឌ ២៤។

- ពីភាគីទាំងអស់ និងពីអង្គជំនុំជម្រះ នូវបញ្ជីឯកសារដែលខ្លួនចង់យកមកប្រើប្រាស់ក្នុងការតាំងសំណួរទៅកាន់រូបលោក ដោយបានបញ្ជាក់ថាបញ្ជីទាំងនោះមានគោលបំណងជួយឱ្យលោក ខៀវ សំផន អាចសិក្សាវិភាគឯកសារទាំងនោះនៅមុនពេលសវនាការ ហើយសូមឱ្យបញ្ជីទាំងនោះមិនត្រូវមានភាពលម្អិត ខ្លាំងពេកនោះទេ ដោយត្រូវស្ថិតក្នុងសមាមាត្រមួយដែលសមរម្យ។
- ពេលត្រៀមចំនួន ៣ សប្តាហ៍ ដោយពុំមានសវនាការ ដែលនឹងត្រូវស្ថិតនៅក្នុងចន្លោះពេលនៃការបញ្ចប់ការបង្ហាញភស្តុតាង និងការសួរសំណួរទៅកាន់រូបលោក ហើយរយៈពេលស្នើសុំនេះត្រូវចាប់គិតពីពេលដែលបានទទួលបញ្ជីដែលស្នើសុំខាងលើ។
- អនុញ្ញាតឱ្យមេធាវីរបស់លោកអាចចូលទៅក្នុងមន្ទីរឃុំឃាំងបាននៅក្នុងថ្ងៃចុងសប្តាហ៍។
- ឱ្យការតាំងសំណួរទៅលើរូបលោកក្នុងអំឡុងពេលសវនាការធ្វើឡើងតែកន្លះថ្ងៃ និងនៅពេលព្រឹក (ជាពេលវេលាដែលសមត្ថភាពផ្ចង់អារម្មណ៍របស់លោកមានលក្ខណៈល្អប្រសើរ)[58]។

៧២. ក្នុងការបង្ហាញសំណើសុំទាំងនេះ មេធាវីការពារក្តីបានរំលឹកដល់អង្គជំនុំជម្រះថា ខ្លួនមានការលំបាក ផ្លូវច្បាប់ដែលមិនត្រូវបានដោះស្រាយ ហើយដែលបានបង្កជាភាពមិនច្បាស់លាស់ធ្វើឱ្យប៉ះពាល់ដល់ សិទ្ធិរបស់លោក ខៀវ សំផន នៅខណៈដែលរូបលោកត្រូវត្រៀមខ្លួនឆ្លើយតបទៅនឹងសំណួរនានា[59]។

៧៣. ពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋានការពារបញ្ចប់ មេធាវីការពារក្តីបានស្នើសុំដល់អង្គជំនុំជម្រះ៖
- ឱ្យផ្ញើជូនខ្លួននូវបញ្ជីចុងក្រោយនៃឯកសារទាំងឡាយដែលមានលេខសម្គាល់ E3[60]។
- ឱ្យផ្តល់នូវថិរវេលាចំនួន ២ សប្តាហ៍ពេញ ដើម្បីធ្វើការពិនិត្យឡើងវិញ និងស្នើសុំកែតម្រូវលើឯកសារ ប្រតិចារិកសវនាការ[61]។

---

[58] សេចក្តីជូនដំណឹង **E288/4** កថាខណ្ឌ ៧ (សូមមើលឯកសារយោងទាំងអស់ដែលបានដកស្រង់)។

[59] សេចក្តីជូនដំណឹង **E288/4** កថាខណ្ឌ ៨ (សូមមើលឯកសារយោងទាំងអស់ដែលបានដកស្រង់)។

[60] កំណត់សម្គាល់របស់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីកិច្ចប្រជុំរៀបចំសវនាការនាថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E288/2** ("កំណត់សម្គាល់មុនកិច្ចប្រជុំរៀបចំសវនាការ **E288/2**") កថាខណ្ឌ ២៣-២៥, ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/207.1** ទំព័រ ៤២ បន្ទាត់ ២៥ ដល់ទំព័រ ៤៤ បន្ទាត់ ១ (ភាសាបារាំង)។

[61] កំណត់សម្គាល់មុនកិច្ចប្រជុំរៀបចំសវនាការ **E288/2** កថាខណ្ឌ ១៩-២២, ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/207.1** ទំព័រ ៤៤ បន្ទាត់ ៣ ដល់ទំព័រ ៤៥ បន្ទាត់ ២ (ភាសាបារាំង)។

- ឲ្យផ្តល់នូវថិរវេលាពី ២ ទៅ ៣ ខែ សម្រាប់ធ្វើការតាក់តែងសារណា និងសេចក្តីសន្និដ្ឋានការពារបញ្ចប់[62]។
- ការកម្រិតចំនួនទំព័រសម្រាប់សារណាបញ្ចប់យ៉ាងហោចណាស់ត្រឹម ៣00 ទំព័រ ហើយថិរវេលានៃការការពារបញ្ចប់ត្រូវមាន ៤ ថ្ងៃ ហើយរយៈពេល ១ ថ្ងៃ សម្រាប់ជនជាប់ចោទឡើងធ្វើសេចក្តីថ្លែងការណ៍ចុងក្រោយរបស់ខ្លួន ដើម្បីអាចឲ្យមេធាវីការពារក្តីមានលទ្ធភាពពិភាក្សាលើឯកសារភ័ស្តុតាង ទាំងមូលដែលបានដាក់ដោយភាគី[63]។
- ថិរវេលានៃការត្រៀមរៀបចំសេចក្តីសន្និដ្ឋានការពារបញ្ចប់ ត្រូវចាប់ផ្តើមគិតតាំងពីពេលដែលទទួលបានសារណាពីភាគីម្ខាងទៀតដែលត្រូវបានធ្វើជាភាសាមួយក្នុងចំណោមភាសាទាំងពីរដែលជនជាប់ចោទអាចយល់បាន (ភាសាបារាំងជាអទិភាព ដោយហេតុថា បុគ្គលិកដែលបម្រើការក្នុងក្រុមមេធាវី ការពារក្តីលោក ខៀវ សំផន មួយភាគធំ ជាអ្នកប្រើប្រាស់ភាសាបារាំង ហើយពុំមែនជាអ្នកប្រើប្រាស់ភាសាខ្មែរនោះទេ)[64]។

៧៥. ផ្អែកលើវិធានច្បាប់ដែលអនុវត្តនៅ អ.វ.ត.ក. ជនជាប់ចោទមានសិទ្ធិទទួលបាននូវថិរវេលា និងមធ្យោបាយងាយស្រួលចាំបាច់នានាសម្រាប់ត្រៀមរៀបចំការពារខ្លួននៅចំពោះមុខតុលាការ[65]។ ជា ឧទាហរណ៍ អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា បានលើកឡើង *"ដូចគ្នាទៅនឹងគណៈកម្មាធិការសិទ្ធិមនុស្សដែរថា "ថិរវេលាចាំបាច់" ក្នុងការត្រៀមរៀបចំការពារក្តី មិនអាចត្រូវបានទទួលយកក្នុងភាពអរូបិយ៍នោះទេ ហើយវាត្រូវតែពឹងផ្អែកលើស្ថានភាពជាក់ស្តែង។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍យល់ឃើញថា ករណីដូចគ្នានេះក៏ត្រូវអនុវត្តផងដែរទៅលើករណី "មធ្យោបាយងាយស្រួលចាំបាច់"។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បាន*

[62] កំណត់សម្គាល់មុនកិច្ចប្រជុំរៀបចំសវនាការ **E288/2** កថាខណ្ឌ ១៤-១៦, ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/207.1** ទំព័រ ៤៥ បន្ទាត់ ៤-៧ (ភាសាបារាំង)។

[63] កំណត់សម្គាល់មុនកិច្ចប្រជុំរៀបចំសវនាការ **E288/2** កថាខណ្ឌ ១១, ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/207.1** ទំព័រ ១៤ បន្ទាត់ ៨-១០, ទំព័រ ៤៥ បន្ទាត់ ៧ ដល់ទំព័រ ៤៦ បន្ទាត់ ១០ (ភាសាបារាំង)។

[64] កំណត់សម្គាល់មុនកិច្ចប្រជុំរៀបចំសវនាការ **E288/2** កថាខណ្ឌ ១៧, ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/207.1** ទំព័រ ៤៥ បន្ទាត់ ២០ ដល់ទំព័រ ៤៦ បន្ទាត់ ៧ (ភាសាបារាំង)។

[65] មាត្រា ១៤ (៣) (ខ) នៃកាតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ៦ នៃកិច្ចព្រមព្រៀងអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស, មាត្រា ៣១ និង ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ១៣ (១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា, មាត្រា ៣៥ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

*បន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានភារកិច្ច ខណៈពេលដែលភាគីណាមួយស្នើសុំដល់ខ្លួនឱ្យជួយដល់ពួកគេ ក្នុងការបង្ហាញអំពីបុព្វហេតុរបស់ខ្លួន ព្រមទាំងចាត់វិធានការនានាដែលអង្គជំនុំជម្រះត្រូវផ្ដល់ដល់ភាគី"* [66]។

៧៥. នៅទីនេះ អង្គជំនុំជម្រះគ្រាន់តែបានស្នើសុំដល់ភាគី *"ឱ្យធ្វើការជូនដំណឹង ក្នុងកាលៈទេសៈមួយសមស្រប ដល់ភាគីដទៃទៀត ព្រមទាំងអង្គជំនុំជម្រះ អំពីឯកសារទាំងឡាយ ដែលភាគីមានបំណងប្រើប្រាស់ក្នុងការតាំងសំណួរមកលើជនជាប់ចោទ"* ។ អង្គជំនុំជម្រះបានបដិសេធសំណើសុំដែលនៅ សេសសល់របស់មេធាវីការពារក្ដី ដោយពុំបានពិចារណាទៅលើកាលៈទេសៈដោយឡែកនៃអង្គហេតុជាក់ស្ដែង[67] ដែលត្រូវបានបកស្រាយលម្អិតផ្ទាល់មាត់ ព្រមទាំងនៅក្នុងសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដែលបានដាក់ពាក់ព័ន្ធនឹងបញ្ហានេះ។ មេធាវីការពារក្ដីសូមស្នើដល់អង្គជំនុំជម្រះតុលាការកំពូលមេត្តាផ្អែកលើខ្លឹមសារទាំងស្រុងនៃសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ព្រមទាំងការលើកឡើងផ្ទាល់មាត់ទាំងនេះ[68]។ ក្រោយមកទៀត ដោយមានការស្នើសុំរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះធ្វើហាក់ដូចជាខ្លួនទទួលយកសំណើសុំឱ្យមានការទុកថិរវេលាត្រៀមរៀបចំការពារក្ដី ហើយពុំបានសម្រេចលើករណីផ្សេងពីនេះឡើយ[69]។

---

[66] តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា *Nahimana និងអ្នកផ្សេងទៀត ទល់នឹងរដ្ឋអាជ្ញា* រឿងក្ដីលេខ ICTR-99-52-A សាលដីកា ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ២២០ និងកំណត់សម្គាល់ជើងទំព័រ ៥៣២ និង ៥៣៣, គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្ដីសង្កេតទូទៅលេខ ៣២ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧ កថាខណ្ឌ ៣២ និង ៣៣។

[67] សេចក្ដីជូនដំណឹង **E288/4** កថាខណ្ឌ ៩ (សូមមើលឯកសារយោងទាំងអស់ដែលបានដកស្រង់), អ៊ីមែលរបស់លោក Kenneth ROBERTS មានកម្មវត្ថុ៖ "កាលវិភាគសវនាការ" ផ្ញើជូនភាគី នៅថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០១៣ វេលាម៉ោង ៨ និង ២៩ នាទី (នៅក្នុងអ៊ីមែលនោះ គ្រោងថា លោក ខៀវ សំផន ផ្ដល់សក្ខីកម្ម នៅរៀងរាល់ពេលរសៀល), ប្រតិចារឹកសវនាការ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ **E1/227.1** ទំព័រ ៧៥ បន្ទាត់ ១៨ ដល់ទំព័រ ៧៧ បន្ទាត់ ២៣ (ភាសាបារាំង), *ការបញ្ជាក់ពីកាលបរិច្ឆេទនៃការដាក់សារណា និងសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល* ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ **E295**។

[68] កំណត់សម្គាល់មុនកិច្ចប្រជុំរៀបចំសវនាការ **E288/2**, ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/207.1** ទំព័រ ៤០ បន្ទាត់ ២២ ដល់ទំព័រ ៤៦ បន្ទាត់ ១០ (ភាសាបារាំង), សេចក្ដីជូនដំណឹង **E288/4**។

[69] ប្រតិចារឹកសវនាការ ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ **E1/220.1** ទំព័រ ៤១ បន្ទាត់ ១៧ ដល់ទំព័រ ៤២ បន្ទាត់ ២ (ភាសាបារាំង)។

៧៦. ជាមួយគ្នានេះ អង្គជំនុំជម្រះពុំបានគោរពទៅតាមគោលការណ៍ដែលថា ជនជាប់ចោទត្រូវទទួលបាននូវឯកសារជាភាសាដែលខ្លួនយល់ ដើម្បីខ្លួនអាចពិភាក្សាទៅលើឯកសារទាំងនោះបាន[70]។ អង្គជំនុំជម្រះពុំបានគោរពតាមការរំលឹករបស់អង្គជំនុំជម្រះតុលាការកំពូលពាក់ព័ន្ធនឹងបញ្ហានេះឡើយ[71]។

៧៧. ជាចុងក្រោយ ការបដិសេធរបស់អង្គជំនុំជម្រះក្នុងការទទួលយកផលវិបាកជាអវិជ្ជមាន ដែលអាចនាំទៅរកការបិទកិច្ចពិភាក្សាទៅលើដំណើរការនៃរឿងក្តី និងទៅលើសិទ្ធិរបស់មេធាវីការពារក្តីខណៈដែលបណ្តឹងសារទុក្ខពាក់ព័ន្ធនឹងសេចក្តីសម្រេចបំបែកសំណុំរឿង ពុំទាន់ត្រូវបានសម្រេចសេចក្តី[72] បានបង្ហាញឱ្យឃើញយ៉ាងច្បាស់អំពីចេតនារបស់ចៅក្រម ក្នុងការបដិសេធផ្តល់នូវមធ្យោបាយចាំបាច់ដល់ មេធាវីការពារក្តីដើម្បីត្រៀមរៀបចំការពារក្តី។

## ខ. <u>ការគ្មានអន្ទះក្នុងការផ្តល់នូវមធ្យោបាយដើម្បីពិភាក្សាលើធាតុផ្សំភស្តុតាង</u>

៧៨. ចាប់តាំងពីដើមដំបូងនៃការជំនុំជម្រះក្តី មេធាវីការពារក្តីបានធ្វើការតវ៉ា ដោយហេតុថា ខ្លួនពុំមានមធ្យោបាយខាងពេលវេលា និងសម្ភារៈ ក្នុងការពិនិត្យមើលឯកសារចំនួនរាប់ពាន់ទំព័រដែលបានស្នើ

[70] មាត្រា ១៤ (៣) (ក) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩ ឯកសារ **A190/I/20** កថាខណ្ឌ ៣៧, ៣៨, ៤៣។ ជាក់ស្តែង ដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាចំនួន ២២៥ ទំព័រ និងសេចក្តីសន្និដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១០៥ ទំព័រ ដែលនឹងត្រូវដាក់នៅថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៣ នឹងមិនត្រូវបានបកប្រែជាភាសាខ្មែរ និងបារាំងឡើយ នៅមុនពេលសវនាការបញ្ចប់ការពិភាក្សាដេញដោលពីថ្ងៃទី ០៩ ដល់ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៣ (ឯកសារទាំងនោះត្រូវបានបកប្រែនៅថ្ងៃធ្វើការ ដែលមានចំនួន ១៤ ថ្ងៃ ដោយក្នុងមួយថ្ងៃអ្នកបកប្រែម្នាក់បកបាន ៤ ទំព័រ ជាមធ្យម)។

[71] សេចក្តីសម្រេចលើសំណើរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន សុំឱ្យអង្គជំនុំជម្រះតុលាការកំពូលជូនដំណឹងជាបីភាសាផ្លូវការ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **E163/5/1/15** កថាខណ្ឌ ៤, ៥, ៧, ៨។ នៅក្នុងឯកសារនោះ បានគូសបញ្ជាក់យ៉ាងច្បាស់លាស់ជាអាទិ៍អំពីសារៈសំខាន់នៃការយល់ ដើម្បីរៀបចំទឡ្ហីករណ៍រឹងមាំ សម្រាប់ពេលសវនាការ។

[72] *សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺ* អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E284/2/1/2** កថាខណ្ឌ ៦។ សូមមើលផងដែរនូវកថាខណ្ឌ ៩៖ *"មេធាវីការពារក្តីពុំត្រូវបានបង្ខំឱ្យធ្វើបទបង្ហាញអំពីទឡ្ហីករណ៍ចុងក្រោយរបស់ខ្លួន មុនពេលដឹងពីវិសាលភាពនៃការជំនុំជម្រះ"*។

ដោយភាគីដទៃទៀត។ ក្រុមមេធាវីការពារក្តីបានស្នើសុំលទ្ធភាពជាក់ស្តែង និងប្រកបដោយប្រសិទ្ធភាព ក្នុងការពិភាក្សាដេញដោលទៅលើឯកសារភ័ស្តុតាងនីមួយៗដែលបានដាក់[73]។

៧៩. នៅពេលចាប់ផ្តើមសវនាការលើអង្គសេចក្តី អង្គជំនុំជម្រះបានទុកថិរវេលាដ៏សែនខ្លី សម្រាប់ឱ្យភាគីធ្វើការដាក់ឯកសារជំទាស់លើភាពដែលមិនអាចទទួលយកបាននៃឯកសារដែលមានចំនួនរាប់ពាន់ទំព័រទាំងនោះ[74]។ ខាងក្រោមនេះគឺជាអ្វីដែលអង្គជំនុំជម្រះបានប្រកាសដល់ភាគីដើម្បីឱ្យពួកគេមានការស្ងប់ចិត្ត៖

*"ថ្វីបើអង្គជំនុំជម្រះពុំបានកំណត់ចំនួនទំព័រនៃសេចក្តីជំទាស់របស់ភាគីក្តី ក៏អង្គជំនុំជម្រះស្នើសុំឱ្យភាគីបញ្ជាក់ឱ្យបានច្បាស់លាស់ដោយសង្ខេបអំពីចំណុចដែលខ្លួនជំទាស់ ពាក់ព័ន្ធនឹងឯកសារ និងវត្ថុតាងនីមួយៗ ឬប្រភេទនៃឯកសារ ឬវត្ថុតាង និងការជំទាស់ជាក់លាក់ដែលបានលើកឡើង។ ភាគីត្រូវធ្វើដូច្នេះ ដោយយោងទៅតាមលក្ខខណ្ឌនៃវិធាន ៨៧ (៣) ... នាដំណាក់កាលនេះ អង្គជំនុំជម្រះនឹងពុំទទួលយកពាក្យសុំណាមួយពាក់ព័ន្ធនឹងតម្លៃជាភ័ស្តុតាង ឬទម្ងន់នៃឯកសារ ឬវត្ថុតាងណាមួយឡើយ។[75]"*

៨០. ជាក់ស្តែង កាលពីពេលនោះ ដោយមើលឃើញថាខ្លួនមានមធ្យោបាយតិចតួច មេធាវីការពារក្តីពុំមានជម្រើសអ្វីផ្សេងក្រៅតែពីការលើកឡើងតាមប្រភេទនីមួយៗ[76]។ សេចក្តីជំទាស់អំពីភាពដែលមិនអាចទទួលយកបាននឹងត្រូវបានបដិសេធចោល ដោយហេតុថាសេចក្តីជំទាស់នោះពុំសូវមាន

---

[73] សំណើសុំពន្យារពេលដាក់ឯកសារភ័ស្តុតាង ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ **E9/6** កថាខណ្ឌ ១៦-៣១, ការដាក់បញ្ជីឯកសារ និងភ័ស្តុតាង-ការស្នើសុំព្យារថិរវេលា ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១ ឯកសារ **E9/16/2** កថាខណ្ឌ ៨-១៤, បញ្ជីឯកសារ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារ **E9/29** កថាខណ្ឌ ៥-១៤។

[74] អនុស្សរណៈ **E131/1** ទំព័រ ២ កថាខណ្ឌទីមួយ និងទីពីរ។

[75] អនុស្សរណៈ **E131/1** ទំព័រ ២ កថាខណ្ឌទីបី (យើងគូសបន្ទាត់ពីក្រោម)។

[76] សេចក្តីជំទាស់មិនទទួលយកបញ្ជីឯកសារ ដែលដាក់ដោយភាគីផ្សេងទៀត សម្រាប់ការជំនុំជម្រះដំណាក់កាលដំបូង (ពីថ្ងៃទី ២៨ ខែ វិច្ឆិកា ដល់ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១) ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ **E131/6**, សេចក្តីជំទាស់មិនទទួលយកបញ្ជីឯកសារសេសសល់ដែលដាក់ដោយភាគីផ្សេងទៀត សម្រាប់ការជំនុំជម្រះដំណាក់កាលដំបូងទាំងបួន ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១១ ឯកសារ **E131/1/11**, សូមមើលផងដែរការជំទាស់ដែលមេធាវី គង់ សំអុន បានលើកឡើង ក្នុងអំឡុងសវនាការពីថ្ងៃទី ១៧ ដល់ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១៣ ឯកសារ **E1/28.1**, **E1/29.1**, **E1/30.1**។

ភាពលម្អិត ឬពុំសូវជាក់លាក់[77]។

៨១. ក្នុងអំឡុងប៉ុន្មានខែដំបូងនៃការធ្វើសវនាការលើអង្គសេចក្តី អង្គជំនុំជម្រះបានកម្រិតទំហំនៃភាពដែលអាចទទួលយកបានយ៉ាងទាបបំផុត និងបានទទូចដាច់ខាតទៅលើការបែងចែកឱ្យដាច់ពីគ្នារវាងភាពដែលអាចទទួលយកបាន និងតម្លៃជាភ័ស្តុតាងនៃឯកសារ។ អង្គជំនុំជម្រះតែងតែរំលឹកជាប្រចាំពាក់ព័ន្ធនឹងការជជែកពិភាក្សាចំនួនពីរដែល"មានលក្ខណៈផ្សេង"[78] ពីគ្នា ហើយបានបញ្ជាក់ថា ការពិភាក្សាទៅលើតម្លៃជាភ័ស្តុតាងនៃឯកសារ គឺជា"ការពិភាក្សាលើអង្គសេចក្តី" ដែលនឹងត្រូវធ្វើនាពេល"ក្រោយ"[79] នឹង"ត្រូវបានពិនិត្យនាពេលក្រោយ"[80] "នាចុងបញ្ចប់នៃរឿងក្តី" ក្នុងពេលដែលមានការពិនិត្យទៅលើ"ភ័ស្តុតាងទាំងមូល"[81] "*នៅពេលដែលការបង្ហាញអំពីធាតុផ្សំ ភ័ស្តុតាងត្រូវបានបញ្ចប់ និងក្នុងអំឡុងពេលដែលមានសវនាការលើអង្គសេចក្តី*"[82]។

៨២. ជាឧទាហរណ៍ នាខែ មីនា ឆ្នាំ ២០១២ នៅក្នុងអំឡុងពេលដែលមានសវនាការពិភាក្សាលើភាពដែល អាចទទួលយកបាន លោកស្រីចៅក្រម CARTWRIGHT បានប្រកាសថា៖
"*យើងនឹងពុំមានពេលវេលាសម្រាប់បើកឱ្យមានកិច្ចពិភាក្សាទៅលើតម្លៃជាភ័ស្តុតាងនៃឯកសារឡើយ។ រាល់បញ្ហាទាំងឡាយដែលពាក់ព័ន្ធទៅលើរឿងនេះ នឹងអាចត្រូវបានបង្ហាញបន្តិចម្តងៗស្របពេលដែលឯកសារត្រូវបានគេដាក់បញ្ចូលទៅក្នុងកិច្ចពិភាក្សា ក៏ដូចជា<u>នៅពេលដែលភាគីត្រូវ</u>*

[77] សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងឧសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ ឯកសារ **E185** កថាខណ្ឌ ២៣។

[78] ប្រតិចារឹកសវនាការ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ ឯកសារ **E1/34.1** ទំព័រ ៩២ បន្ទាត់ ៧-៩ (ភាសាបារាំង), ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងផ្នែកខ្លះនៃឯកសារ E/114, E/114.1, E131/1/9, E131/6, E136 និង E158 ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ ឯកសារ **E162** កថាខណ្ឌ ២ និង ៤, សេចក្តីសម្រេច **E185/1** កថាខណ្ឌ ១៣។

[79] ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ **E1/23.1** ទំព័រ ៦៤ បន្ទាត់ ៥-១១ (ភាសាបារាំង)។

[80] ប្រតិចារឹកសវនាការ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២ ឯកសារ **E1/24.1** ទំព័រ ៦៤ បន្ទាត់ ១៣-១៦ (ភាសាបារាំង)។

[81] *ការកំណត់កាលបរិច្ឆេទនៃសវនាការផ្ទាល់មាត់លើឯកសារនានា (ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១៦ ដល់ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២)* ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ ឯកសារ **E159** កថាខណ្ឌ ៦។

[82] សេចក្តីសម្រេច **E185** កថាខណ្ឌ ២១ និងកថាខណ្ឌចុងក្រោយនៃសេចក្តីសម្រេច។

*ឡើងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់*"[83]។

៨៣. ប៉ុន្មានសប្តាហ៍មុនពេលដែលមានការរំលឹកនេះ ហើយខណៈដែលកិច្ចពិភាក្សាពាក់ព័ន្ធនឹងភាពដែលអាចទទួលយកបានទើបតែនឹងចាប់ផ្តើម អង្គជំនុំជម្រះបានសម្រេចបើកសវនាការលើកដំបូងពាក់ព័ន្ធនឹងការបង្ហាញ "ឯកសារគន្លឹះ"។ អង្គជំនុំជម្រះបានប្រកាសថា សវនាការប្រភេទនេះមានគោលដៅបើកឱ្យសាធារណជនអាចស្វែងយល់អំពីឯកសាររបស់តុលាការ ដោយអនុញ្ញាតឱ្យភាគីធ្វើចំណាប់អារម្មណ៍ទៅលើឯកសារទៅលើឯកសារដែលខ្លួនយល់ឃើញថាមានភាពសមស្រប។ ដោយចម្លែកបំផុត មានតែជនជាប់ចោទប៉ុណ្ណោះ ដែលមាន"*ឱកាស*" ក្នុងការបញ្ចេញយោបល់ទៅលើឯកសារដែលបានបង្ហាញនោះ។ សវនាការទាំងនេះពុំមានជាប់ពាក់ព័ន្ធទៅនឹងភាពដែលអាចទទួលយកបាន និងតម្លៃជាភ័ស្តុតាងនៃឯកសារដែលបានបង្ហាញនោះទេ ហើយមេធាវីការពារក្តីក៏ពុំត្រូវបានទុកពេលវេលាឱ្យធ្វើការឆ្លើយតបដែរ[84]។

៨៤. មេធាវីការពារក្តីលោក ខៀវ សំផន បានធ្វើការជំទាស់ភ្លាមៗទៅនឹងការបើកឱ្យមានសវនាការប្រភេទនេះ ដែលពុំបើកឱ្យមានការពិភាក្សាដេញដោលចំពោះមុខ ឬក៏ធាតុផ្សំនៃការការពារក្តីណាមួយនោះ។ មេធាវីការពារក្តីលោក ខៀវ សំផន បានបដិសេធមិនចូលរួមក្នុងសវនាការនោះឡើយ។ នាដើមឆ្នាំ ២០១៣ នៅក្នុងអំឡុងនៃការធ្វើសវនាការលើកទីបីពាក់ព័ន្ធនឹងឯកសារគន្លឹះ អង្គជំនុំជម្រះធ្វើហាក់ដូចជាអនុញ្ញាតឱ្យមានសិទ្ធិឆ្លើយតបស្រដៀងគ្នានេះ។ មេធាវីការពារក្តីបានដាក់សំណើសុំជាលាយលក្ខណ៍អក្សរដ៏វែងអន្លាយរបស់ខ្លួន ដើម្បីបង្ហាញអំពីកង្វល់របស់ខ្លួនពាក់ព័ន្ធទៅនឹងការគោរពសិទ្ធិជាមូលដ្ឋានរបស់លោក ខៀវ សំផន។ មេធាវីការពារក្តីបានស្នើសុំឱ្យមានការបញ្ឈប់សវនាការទាំងនេះ និងការធានាថានឹងមានការពិភាក្សានាពេលក្រោយទៅលើតម្លៃនៃឯកសារភ័ស្តុតាងទាំងមូល នៅពេលដែលឯកសារទាំងនោះត្រូវបានគេបង្ហាញឡើង។ មេធាវីការពារក្តីសូមស្នើសុំដល់អង្គជំនុំជម្រះតុលាការកំពូល មេត្តាពិនិត្យលើឯកសារជាលាយលក្ខណ៍អក្សរនេះទាំងមូល[85]។

---

[83] ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ឯកសារ **E1/47.1** ទំព័រ ២ បន្ទាត់ ៥-៩ (ភាសាបារាំង)។

[84] សូមមើលឯកសារយោងទាំងអស់ កថាខណ្ឌ ៥ និងឧបសម្ព័ន្ធទាំងឡាយនៃសំណើសុំរបស់មេធាវីការពារក្តីលោក ខៀវ សំផន ដែលអះអាងសាជាថ្មីអំពីសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្តី ដោយគោរពគោលការណ៍ចំពោះមុខ និងដោយយុត្តិធម៌ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ **E263**។

[85] សំណើសុំរបស់មេធាវីការពារក្តីលោក ខៀវ សំផន ដែលអះអាងសាជាថ្មីអំពីសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្តី

៨៥. ដោយឡែក ប៉ុន្មានសប្តាហ៍ក្រោយពេលដែលសវនាការលើអង្គសេចក្តីបានបញ្ចប់ទៅ ហើយពាក់ព័ន្ធនឹងការឆ្លើយតបទៅនឹងភាពកង្វល់របស់មេធាវីការពារក្តីលោក ខៀវ សំផន អង្គជំនុំជម្រះនឹងធ្វើការអះអាងដែលមានលក្ខណៈបែបអត្ថានិយមទាំងស្រុង ដោយហេតុថាវាមានលក្ខណៈផ្ទុយគ្នាទាំងស្រុងទៅនឹងសេចក្តីជូនដំណឹងកាលដែលបានធ្វើកាលពីពេលមុន ដែលបានបើកឱ្យមានសវនាការលើឯកសារគន្លឹះនោះ អង្គជំនុំជម្រះបានអះអាងថា នៅខណៈពេលដែលមានសវនាការទាំងនេះ ភាគី "*តែងតែមានលទ្ធភាពក្នុងការជំទាស់ទៅនឹងភាពសមស្រប ឬតម្លៃជាភស្តុតាងនៃឯកសារដែលបានបង្ហាញឡើងដោយភាគី*"[86]។ នៅក្នុងពេលជាមួយគ្នានោះដែរ អង្គជំនុំជម្រះបានកម្រិតក្របខណ្ឌនៃទីកន្លែងពិតប្រាកដនៃការពិភាក្សាទៅលើតម្លៃនៃធាតុផ្សំភស្តុតាង ពោលគឺសេចក្តីសន្និដ្ឋានបញ្ចប់ និងសារណាការពារបញ្ចប់[87]។

៨៦. ជាចុងក្រោយ នៅក្នុងអំឡុងនៃសវនាការចុងក្រោយដែលពិភាក្សាលើឯកសារគន្លឹះ អង្គជំនុំជម្រះនឹងធ្វើការប្រកាសថា ភាគីអាចពិភាក្សាបានគ្រប់បញ្ហា លើកលែងតែពាក់ព័ន្ធនឹងភាពដែលអាចទទួលយកបាន (ដែលបញ្ហានេះប្រហែលជាត្រូវបានសម្រេចរួចហើយ)[88]។ ដូច្នេះ អ្វីដែលត្រូវពិភាក្សាគឺពាក់ព័ន្ធនឹងភាពសមស្រប និងតម្លៃជាភស្តុតាងនៃឯកសារទាំងនោះ[89]។ ដោយឡែក ភាពសមស្របគឺជាលក្ខខណ្ឌនៃភាពដែលអាចទទួលយកបាន... ដូច្នេះ យើងសង្កេតឃើញអំពីភាពយល់ច្រលំរបស់អង្គជំនុំជម្រះ ដែលទោះបីជាមានការបដិសេធជាដរាបពីសំណាក់មេធាវីការពារក្តីលោក ខៀវ សំផន ក្នុងការចូលរួមសវនាការក្រៅការជំនុំជម្រះក៏ដោយ បានផ្តល់រយៈពេល ២ ម៉ោង (ដោយមានការស្នើសុំពីសំណាក់សហព្រះរាជអាជ្ញា) "*ដើម្បីលើកឡើងនូវកំណត់សម្គាល់របស់ខ្លួនពាក់ព័ន្ធនឹងឯកសារ ដែលបង្ហាញដោយភាគីដទៃទៀតក្នុងសវនាការ ឬក៏ដើម្បីលើកឡើងនូវចំណុច*

---

ដោយគោរពគោលការណ៍ចំពោះមុខ និងដោយយុត្តិធម៌ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ **E263**។

[86] អនុស្សរណៈ **E288/1/1** កថាខណ្ឌ ៥។

[87] អនុស្សរណៈ **E288/1/1** កថាខណ្ឌ ១០-១២។

[88] ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/207.1** ទំព័រ ២០ បន្ទាត់ ៩-២២ (ភាសាបារាំង)។

[89] ប្រតិចារឹកសវនាការ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/213.1** ទំព័រ ៥៥ បន្ទាត់ ២៤ ដល់ទំព័រ ៥៦ បន្ទាត់ ៤ (ភាសាបារាំង)។

*សំខាន់ៗនៃកំណត់ហេតុជាឯកសារពីទស្សនៈរបស់ភាគីនោះ*"[90]។ សំណើរបស់អង្គជំនុំជម្រះអាចជាការដាក់សំពាធទ្វេដង៖ ប្រសិនណាជាមេធាវីការពារក្តីមិនមានឱកាសក្នុងការដេញដោលលើឯកសារដែលមានចំនួនរាប់រយទំព័រ ក្នុងរយៈពេលពីរម៉ោងបានទេ អង្គជំនុំជម្រះ"*នឹងមានសិទ្ធិបដិសេធរាល់សំណើសុំថ្មីទាំងអស់ ដែលស្នើឱ្យមានការផ្តល់រយៈពេលបន្ថែម ឬអនុញ្ញាតឱ្យមានការបន្ថែមចំនួនទំព័រសម្រាប់សេចក្តីសន្និដ្ឋានបញ្ចប់ ឬសារណាការពារបញ្ចប់របស់ខ្លួន*' (ដែលអង្គជំនុំជម្រះក៏បានអះអាងផងដែរថា ខ្លួននឹងបដិសេធសំណើសុំទាំងនោះ)[91]... ភាពច្របូកច្របល់របស់អង្គជំនុំជម្រះទៅលើក្របខណ្ឌនៃសវនាការសម្រេចអំពីឯកសារគន្លឹះ និងការបង្ហាញចំពោះមុខ ដែលអង្គជំនុំជម្រះបានធ្វើជាច្រើនលើកច្រើនសា គឺជាភ័ស្តុតាងបន្ថែមមួយដែលបង្ហាញអំពីអស្ថេរភាពគតិយុត្តិនៃសំណុំរឿង ០០២/០១។ ដោយមើលឃើញយ៉ាងច្បាស់ថា អង្គជំនុំជម្រះបានរំលោភយ៉ាងជាក់ស្តែងទៅលើគោលការណ៍នៃការពិភាក្សាចំពោះមុខ អង្គជំនុំជម្រះបានព្យាយាមធ្វើការកែតម្រូវយ៉ាងគ្រាំគ្រង និងមិនពេញលេញ ដោយបានផ្តល់ពេលវេលាចំនួន ២ ម៉ោង ដល់មេធាវីការពារក្តីក្នុងសវនាការចុងក្រោយនេះ។

៨៧. ដោយឡែក ការព្រួយបារម្ភរបស់មេធាវីការពារក្តីលោក ខៀវ សំផន អំពីការណ៍ដែលថា កិច្ចពិភាក្សាដេញដោលចំពោះមុខមួយមិនអាចធ្វើទៅកើតក្នុងអំឡុងពេលសវនាការលើឯកសារគន្លឹះ កង្វល់នោះត្រូវបានបញ្ជាក់តាមរយៈការបកស្រាយរបស់មេធាវីការពារក្តីលោក នួន ជា ដែលកាលពីថ្ងៃទី ៨ និង ៩ ខែ កក្កដា ឆ្នាំ ២០១៣ ត្រូវបានរាំងមិនឱ្យធ្វើការពិភាក្សាអំពីតម្លៃជាភ័ស្តុតាងនៃឯកសារដែលបានបង្ហាញ[92]។ មេធាវីការពារក្តីលោក ខៀវ សំផន យល់ឃើញថា ខ្លួនមិនអាច"*លើកឡើងនូវចំណុច សំខាន់ៗនៃទស្សនៈរបស់ខ្លួនដោយផ្ទុះបញ្ចាំងទៅលើទិដ្ឋភាពទាំងអស់នៃភ័ស្តុតាងជាឯកសារទាំងឡាយដែលត្រូវបានទទួលយកក្នុងអំឡុងនៃការជំនុំជម្រះក្តី*"[93]។

---

[90] អនុស្សរណៈ **E288/1/1** កថាខណ្ឌ ៦។

[91] អនុស្សរណៈ **E288/1/1** កថាខណ្ឌ ៦ និង ១០។

[92] ឧទាហរណ៍ សូមមើល៖ ប្រតិចារឹកសវនាការ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ **E1/119.1** ទំព័រ ៤៨ បន្ទាត់ ២០ ដល់ទំព័រ ៥០ បន្ទាត់ ១២, ទំព័រ ១១៤ បន្ទាត់ ២ ដល់ទំព័រ ១២០ បន្ទាត់ ១៥ (ភាសាបារាំង), ប្រតិចារឹកសវនាការ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ **E1/220.1** ទំព័រ ២ បន្ទាត់ ១៦ ដល់ទំព័រ ៤ បន្ទាត់ ២៤ (ភាសាបារាំង)។

[93] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ **E1/220.1** ទំព័រ ៧០ បន្ទាត់ ១៨ ដល់ទំព័រ ៧២ បន្ទាត់ ២១ (ភាសាបារាំង)។

៨៨. ជាមួយគ្នានេះ ផ្ទុយទៅនឹងភាពសមហេតុសមផល ហើយដោយបានរំលោភលើគោលការណ៍បឋមនៃការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ សវនាការអស់រយៈពេលជាច្រើនថ្ងៃត្រូវបានធ្វើដោយឥតប្រយោជន៍ ពាក់ព័ន្ធនឹងការបង្ហាញឯកសារ"គន្លឹះ" ដោយពុំអនុញ្ញាតឱ្យភាគីអាចពិភាក្សាដេញដោលលើឯកសារទាំងនោះ។ អ្វីដែលពុំត្រឹមត្រូវទាល់តែសោះនោះ គឺថាសវនាការលើឯកសារគន្លឹះទាំងនេះត្រូវបានអង្គជំនុំជម្រះប្រើប្រាស់ជាលេសដើម្បីអះអាងថា អង្គជំនុំជម្រះបើកឱ្យមានកិច្ចពិភាក្សាផ្ទាល់មាត់ និងដើម្បីកម្រិតចំនួនទំព័រនៃសារណា និងសេចក្តីសន្និដ្ឋានការពារបញ្ចប់។

៨៩. ត្រង់ចំណុចនេះ ត្រូវតែមានការបញ្ជាក់បន្ថែមថា នៅខណៈដែលមានការបិទការបង្ហាញភស្តុតាង និងប៉ុន្មានសប្តាហ៍បន្ទាប់ពីមានការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ (ដែលកាលបរិច្ឆេទត្រូវបានគេកំណត់រួចហើយ!) សេចក្តីសម្រេចពាក់ព័ន្ធនឹងភាពដែលអាចទទួលយកបាននៃឯកសារដែលមានចំនួនរាប់ពាន់ទំព័រត្រូវបានគេព្យួរទុកមួយអន្លើ[94] ហើយក៏ពុំមានបញ្ជីឯកសារក្នុងប្រភេទ E3 ដែលបញ្ជីនោះមានបច្ចុប្បន្នភាព និងជាបញ្ជីស្ថាពរ ត្រូវបានគេផ្តល់ដែរ។ ក្រៅពីនេះ ឯកសារប្រតិចារឹកនៃការផ្តល់សក្ខីកម្មចំនួនរាប់រយទំព័រ ត្រូវបានសង្កេតឃើញថាមានកំហុសនៅក្នុងការបកប្រែទៅជាភាសាផ្សេងៗគ្នា។

៩០. ជាក់ស្តែង កិច្ចពិភាក្សាពេញលក្ខណៈមួយដែលត្រូវបានប្រកាសតាំងពីពេលដែលមានការចាប់ផ្តើមជំនុំជម្រះក្តីពាក់ព័ន្ធទៅនឹងតម្លៃនៃឯកសារភស្តុតាងទាំងមូល (ដែលវិសាលភាពនៅតែពុំត្រូវបានគេកំណត់) នៅតែពុំត្រូវបានធ្វើដដែល។ ដោយឡែក ធាតុផ្សំទាំងនេះហើយដែលអង្គជំនុំជម្រះប្រើប្រាស់ជាមូលដ្ឋាននៃសេចក្តីសម្រេចរបស់ខ្លួន។ ហើយវាគឺជាកម្មវត្ថុនៃការជំនុំជម្រះក្តី។

៩១. បច្ចុប្បន្ននេះ មេធាវីការពារក្តីត្រូវបានដាក់ឱ្យស្ថិតនៅក្នុងកាតព្វកិច្ចពិភាក្សាអំពីតម្លៃនៃសក្ខីកម្មរបស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ចំនួន ៩២ រូប ក៏ដូចជាឯកសារដែលមានចំនួនប្រហែល ៦៣០០ ឯកសារ (ឯកសារប្រហែល ៤០០០ ឯកសារ ត្រូវបានសម្រេចថាមានលក្ខណៈ

[94] ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/207.1** ទំព័រ ២៨ បន្ទាត់ ២៥ ដល់ទំព័រ ២៩ បន្ទាត់ ១៧ (ភាសាបារាំង), ប្រតិចារឹកសវនាការ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ **E1/227.1** ទំព័រ ៧៥ បន្ទាត់ ១៨ ដល់ទំព័រ ៧៦ បន្ទាត់ ៣ (ភាសាបារាំង)។

អាចទទួលយកបាន ហើយឯកសារចំនួន ២៣០០ ឯកសារទៀត ពុំទាន់ត្រូវបានគេសម្រេចទទួលយកនៅឡើយ)[95] តាមរយៈសារណាបញ្ចប់មួយដែលមានចំនួន ១២៥ ទំព័រ និងឡើងការពារក្នុងរយៈពេល ៩ ម៉ោង ៤០ នាទី។ ស្ថានភាពដូច្នេះមិនអាចទទួលយកបានឡើយ សម្រាប់រឿងក្ដីព្រហ្មទណ្ឌអន្តរជាតិក្នុងកម្រិតមួយដូចរឿងក្ដីបច្ចុប្បន្ននេះ។ ក្នុងការបដិសេធនូវមធ្យោបាយចាំបាច់នានាដែលបានលើកឡើងដោយមេធាវីការពារក្ដី ព្រមទាំងលទ្ធភាពពិតប្រាកដរបស់មេធាវីការពារក្ដីក្នុងការពិភាក្សាទៅលើធាតុផ្សំនៃភ័ស្តុតាង ក្នុងអំឡុងពេលនៃកិច្ចពិភាក្សាដេញដោលចំពោះមុខពិតប្រាកដមួយ អង្គជំនុំជម្រះបាន បង្ហាញយ៉ាងច្បាស់អំពីបំណងរបស់ខ្លួនក្នុងការដកមេធាវីការពារក្ដីចេញពីនីតិវិធី។

## គ. ការបដិសេធមិនព្រមស្ដាប់ហេតុផលរបស់មេធាវីការពារក្ដី

៩២. ការបដិសេធពុំព្រមស្ដាប់ហេតុផលដែលលើកឡើងដោយមេធាវីការពារក្ដី ត្រូវបានបង្ហាញឡើងតាមរយៈទង្វើរបស់អង្គជំនុំជម្រះក្នុងការសម្រេចតាមសំណើសុំរបស់សហព្រះរាជអាជ្ញា ខណៈដែលអង្គជំនុំជម្រះពុំទាន់ទាំងបានស្ដាប់ទឡ្ហីករណ៍របស់មេធាវីការពារក្ដីផង[96]។ ជាមួយគ្នានេះមេធាវីការពារក្ដីត្រូវទាមទារសិទ្ធិក្នុងការឆ្លើយតប*នាពេលក្រោយ*របស់ខ្លួន នៅពេលដែលមេធាវីការពារក្ដីនៅមានឱកាស ក្នុងការទាមទារនៅឡើយ[97]។ បញ្ច្រាសមកវិញ សិទ្ធិនេះត្រូវបានប្រគល់ដល់សហព្រះរាជអាជ្ញាទៅវិញ បើទោះបីជាសហព្រះរាជអាជ្ញាពុំបានធ្វើការទាមទារក៏ដោយ[98]។

៩៣. ដូច្នេះ នៅលើទិដ្ឋភាពច្បាប់ យើងមានការព្រួយបារម្ភ ដោយហេតុថា ចៅក្រមអនុញ្ញាតឱ្យមេធាវីការពារក្ដីតាក់តែងឯកសារសំខាន់របស់ខ្លួនជាពីរភាសា (ឧទាហរណ៍ ផ្នែកនៃសារណាបញ្ចប់ដែល

---

[95] ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/207.1** ទំព័រ ២៨ បន្ទាត់ ២៥ ដល់ទំព័រ ២៩ បន្ទាត់ ១៧ (ភាសាបារាំង)។

[96] កំណត់សម្គាល់មុនកិច្ចប្រជុំរៀបចំសវនាការ **E288/2** កថាខណ្ឌ ៣-៤។

[97] ប្រតិចារឹកសវនាការ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/210.1** ទំព័រ ៦១ បន្ទាត់ ១៥ ដល់ទំព័រ ៦៣ បន្ទាត់ ៣ (ភាសាបារាំង)។

[98] សំណើសុំរបស់មេធាវីការពារក្ដីលោក ខៀវ សំផន ដែលអះអាងសាជាថ្មីអំពីសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្ដីដោយគោរពគោលការណ៍ចំពោះមុខ និងដោយយុត្តិធម៌ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ **E263**, ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/207.1** ទំព័រ ២២ បន្ទាត់ ១-៥ (ភាសាបារាំង)។

ពាក់ព័ន្ធនឹងច្បាប់ដែលត្រូវអនុវត្ត)[99] ឬមួយភាសា (ដូចជាករណីសារណាបញ្ចប់)[100] ផ្ទុយទៅវិញ ពាក់ព័ន្ធនឹងឯកសារភ័ស្តុតាងដែលភាគីត្រូវដាក់ អង្គជំនុំជម្រះបែរជាបង្គាប់ឱ្យឯកសារទាំងនោះត្រូវតែបានដាក់ជាបីភាសាទៅវិញ[101]។

៩៤. យើងសង្កេតឃើញផងដែរថា ចៅក្រមបានធ្វើការចោទសួរទៅលើសាក្សីដោយប្រើប្រាស់ធាតុផ្សំនៃភ័ស្តុតាងដែលមានលក្ខណៈផ្ទុយគ្នាទៅនឹងការចោទសួររបស់មេធាវីការពារក្តី[102]។

៩៥. ជាចុងក្រោយ មេធាវីការពារក្តីត្រូវបានគេកាត់ផ្តាច់ឧបករណ៍ស្របសម្លេងរបស់ខ្លួនជាច្រើនលើកច្រើនសា រាប់មិនអស់ ខណៈដែលខ្លួនពុំទាន់បានបញ្ចប់ឃ្លារបស់ខ្លួនចប់សព្វគ្រប់នោះ។ គួរតែលើកឧទាហរណ៍យ៉ាងតិចមួយ ពាក់ព័ន្ធនឹងករណីនេះ ដែលបង្ហាញអំពីទង្វើប្រព្រឹត្តមកលើមេធាវីការពារក្តី និងការដឹកនាំសវនាការពីសំណាក់អង្គជំនុំជម្រះ។

---

[99] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ ឯកសារ **E163/5/9**។ នៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៣ ដោយហេតុថាសេចក្តីសន្និដ្ឋានទាំងនេះ (២០ ទំព័រ) នៅតែមានតែជាភាសាបារាំង និងខ្មែរ មេធាវីការពារក្តីលោក ខៀវ សំផន ក៏បានស្នើសុំបកប្រែជាភាសាអង់គ្លេសដោយខ្លួនឯង។

[100] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់មេធាវីការពារក្តីចំនួន ២២៥ ទំព័រ ដែលនឹងត្រូវដាក់ជាភាសាបារាំង នៅថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៣ នឹងមិនត្រូវបានបកប្រែជាភាសាខ្មែរ និងបារាំងឡើយ នៅមុនពេលសវនាការបញ្ចប់ការពិភាក្សាដេញដោលពីថ្ងៃទី ០៩ ដល់ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៣ (ឯកសារទាំងនេះត្រូវបានបកប្រែនៅថ្ងៃធ្វើការ ដែលមានចំនួន ១៤ ថ្ងៃ ដោយក្នុងមួយថ្ងៃ អ្នកបកប្រែម្នាក់បកបាន ៤ ទំព័រ ជាមធ្យម)។

[101] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ **E1/95.1** ទំព័រ ១១៩ បន្ទាត់ ៤-៨ (ភាសាបារាំង), សេចក្តីសម្រេច **E185/1** កថាខណ្ឌ ១៦, ចម្លើយតបទៅនឹងសំណើ E246 និង E185/1/1 និងសំណើផ្សេងៗមួយចំនួនពាក់ព័ន្ធនឹងឯកសារ និងពេលវេលាកំណត់ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ **E246/1** កថាខណ្ឌ ៣, ប្រតិចារឹកសវនាការថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/207.1** ទំព័រ ៥៣ បន្ទាត់ ១៣-១៧ (ភាសាបារាំង), សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំបង្កើតនីតិវិធីពាក់ព័ន្ធនឹងការទទួលយកឯកសារដែលមិនបានបកប្រែគ្រប់ភាសាទាំងអស់របស់ អ.វ.ត.ក (ឯកសារ E223/2/6) និងចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការដាក់ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងឯកសារផ្សេងៗ (ឯកសារ E223/2/7 និង E223/2/7/1) ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E223/2/6/1** កថាខណ្ឌ ៧។

[102] ប្រតិចារឹកសវនាការ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/208.1** ទំព័រ ៥២ បន្ទាត់ ៩-២៥ (ភាសាបារាំង), សូមមើលផងដែរនូវការសួរចម្លើយរបស់ចៅក្រម ប្រតិចារឹកសវនាការ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/205.1** ទំព័រ ៣៩ បន្ទាត់ ១៣ ដល់ទំព័រ ៤០ បន្ទាត់ ១២ (ភាសាបារាំង) ធៀបនឹងអ្វីដែលបានឆ្លើយប្រាប់មេធាវីការពារក្តីលើកមុន ប្រតិចារឹកសវនាការ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១២ ឯកសារ **E1/132.1** ទំព័រ ៨៥ បន្ទាត់ ១៨ ដល់ទំព័រ ៨៨ បន្ទាត់ ៨ (ភាសាបារាំង)។

៩៦. ក្នុងអំឡុងនៃការចោទសំណួរលើសាក្សី នូ ម៉ៅ មេធាវីការពារក្តីត្រូវបានចៅក្រមកាត់ផ្តាច់ឧបករណ៍ស្រូបសម្លេងចំនួនបីលើក ក្នុងរវាង ៣ នាទី ខណៈដែលមេធាវីការពារក្តីគ្រាន់តែសាកល្បងស្វែងរកព័ត៌មានដែលពាក់ព័ន្ធនឹងការប្រគល់ឯកសារដល់សាក្សី មុនពេលដែលសាក្សីនោះត្រូវមកបង្ហាញខ្លួន នៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារដែលត្រូវបានដាក់ជាឯកសារភ័ស្តុតាង)។ ចៅក្រមបានបង្គាប់ដល់មេធាវីការពារក្តីបន្តការតាំងសំណួររបស់ខ្លួនតទៅទៀត ដោយចូលទៅកាន់ប្រធានបទផ្សេង ដោយចៅក្រមគ្រាន់តែបញ្ជាក់ថា៖ *"លោកមេធាវីអាចលើកសំណួរផ្សេងទៀតបាននាពេលក្រោយ"*[103]។ ដូច្នេះ មេធាវីការពារក្តីត្រូវបានបង្ខំឱ្យដាក់សំណើសុំនាពេលក្រោយប្រសិនណាជាខ្លួនចង់ទទួលបាននូវព័ត៌មានចាំបាច់នោះ[104] សំណើសុំដែលនឹងត្រូវបានបដិសេធចោល ដោយមូលហេតុភាគីមានឱកាសក្នុងការឆ្លើយទៅនឹងសំណួរ ក្នុងពេលដែលមានការតាំងសំណួរទៅលើសាក្សី[105]។

៩៧. នៅក្នុងផ្នត់គំនិតដូចគ្នា ខណៈដែលមេធាវីការពារក្តីប៉ុនប៉ងធ្វើការជំទាស់ទៅនឹងការបង្ហាញ "ឯកសារគន្លឹះសហឧក្រិដ្ឋកម្មរួម" ដែលមិនសមស្រប ដោយហេតុថា ឯកសារទាំងនោះមានជាប់ពាក់ព័ន្ធនឹងរឿងនយោបាយ ដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿងទីមួយ មេធាវីការពារក្តីនឹងត្រូវបានអង្គជំនុំជម្រះចោទប្រកាន់ថាបានបង្កភាពរាំងស្ទះ និងបង្គាប់ឱ្យរងចាំដល់វេនដែលខ្លួនអាចបញ្ចេញមតិបាន[106]។ នៅពេលដល់វេនដែលមេធាវីការពារក្តីឡើងការពារ (ខណៈពេលដែលឯកសារទាំងអស់ត្រូវបានបង្ហាញ) មេធាវីការពារក្តីនឹងត្រូវបានរាំងមិនឱ្យលើកឡើងអំពីបញ្ហានយោបាយ និងអំពីសហឧក្រិដ្ឋកម្មរួម[107]។

---

[103] ប្រតិចារិកសវនាការ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/210.1** ទំព័រ ៣៤ បន្ទាត់ ៥ ដល់ទំព័រ ៣៦ បន្ទាត់ ៥ (ភាសាបារាំង)។

[104] សំណើសុំផ្តល់ព័ត៌មាន ដែលបានដាក់ដោយមេធាវីការពារក្តីលោក ខៀវ សំផន ពាក់ព័ន្ធនឹងលក្ខខណ្ឌនៃការកោះហៅសាក្សី នូ ម៉ៅ ឱ្យចូលខ្លួនមកចំពោះមុខសវនាការ ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ **E266/3/1**។

[105] ប្រតិចារិកសវនាការ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ **E1/227.1** ទំព័រ ៧៤ បន្ទាត់ ៧-៩ (ភាសាបារាំង)។

[106] ប្រតិចារិកសវនាការ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/213.1** ទំព័រ ៥៩ បន្ទាត់ ៥ ដល់ទំព័រ ៦០ បន្ទាត់ ៧ (ភាសាបារាំង)។

[107] ប្រតិចារិកសវនាការ ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ **E1/220.1** ទំព័រ ៨២ បន្ទាត់ ១៦ ដល់ទំព័រ ៨៣ បន្ទាត់ ១៤ (ភាសាបារាំង)។

៩៨. បញ្ច្រាស់មកវិញ ខណៈពេលដែលហេតុការណ៍នេះបានវិវត្តដល់ដំណាក់កាលដែលបានធ្វើឱ្យសហព្រះរាជអាជ្ញាមានការមិនពេញចិត្ត សហព្រះរាជអាជ្ញាបានចាត់ឱ្យមានជាវេទិកាសាធារណៈមួយដើម្បីរៀបចំជាឆាកល្ខោន ដោយបានធ្វើសំណើសុំនាទាក្នុងចេតនាមិនស្មោះត្រង់ដើម្បីដាក់ទណ្ឌកម្មមកលើមេធាវីការពារក្តី[108]។ ទន្ទឹមគ្នានោះ អង្គជំនុំជម្រះនឹងផ្តល់ឱកាសឱ្យសហព្រះរាជអាជ្ញាធ្វើការលើកសំណើសុំផ្ទាល់មាត់ដោយសេរី និងធ្វើការចោទសំណួរក្នុងសវិយាបថឆេវឆាវ ចំណែកឯខាងមេធាវីការពារក្តីវិញ អង្គជំនុំជម្រះនឹងធ្វើការរារាំងមិនឱ្យពួកគេធ្វើដូច្នោះបានឡើយ[109]។

៩៩. ដោយហេតុវាជាការចាំបាច់នៅឡើយក្នុងការបង្ហាញអំពីអត្ថប្រយោជន៍ដែលខ្លួនទទួលបាន អង្គជំនុំជម្រះហាក់ដូចជាភ្លេចកំណត់ចិរវេលាសម្រាប់ជនជាប់ចោទឡើងថ្លែងការពារខ្លួន ដើម្បីឱ្យពួកគេអាចអនុវត្តនូវសិទ្ធិអប្បបរិមារបស់ពួកគេ ក្នុងការធ្វើសេចក្តីថ្លែងការណ៍ចុងក្រោយមួយ[110]។

១០០. ឧទាហរណ៍ទាំងអម្បាលម៉ាននេះ បានបង្ហាញយ៉ាងជាក់ច្បាស់ ពាក់ព័ន្ធនឹងការបដិសេធពុំព្រមស្តាប់

[108] សំណើសុំដាក់ទណ្ឌកម្មលើមេធាវីការពារក្តីកម្ពុជា ដែលមិនលើកឡើងអ្វីក្រៅតែពីកំហុសនៃការបកប្រែប៉ុណ្ណោះ (ប្រតិចារឹកសវនាការ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/206.1** ទំព័រ ៣៧ បន្ទាត់ ១៩ ដល់ទំព័រ ៤៤ បន្ទាត់ ២១ (ភាសាបារាំង)), សំណើសុំដាក់ទណ្ឌកម្មលើក្រុមមេធាវីការពារក្តី បន្ទាប់ពីបានចេញផ្សាយលិខិតចំហមួយច្បាប់នៅលើសារព័ត៌មានភ្នំពេញប៉ុស្តិ៍ ដោយលើកឡើងតែបញ្ហាដែលបានលើកឡើងរួចហើយនៅចំពោះមុខអង្គជំនុំជម្រះ (ប្រតិចារឹកសវនាការ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ **E1/226.1** ទំព័រ ៥២ បន្ទាត់ ១៤ ដល់ទំព័រ ៨១ បន្ទាត់ ១៤ (ភាសាបារាំង))។

[109] ការបដិសេធចំពោះការបង្ហាញដោយផ្ទាល់មាត់អំពីសំណើរបស់មេធាវីការពារក្តី យោងតាមវិធាន ៨៧ (៤) (ឧទាហរណ៍ សូមមើលប្រតិចារឹកសវនាការ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១២ ឯកសារ **E1/75.1** ទំព័រ ២៣ បន្ទាត់ ២៤ ដល់ទំព័រ ២៥ បន្ទាត់ ១៥ (ភាសាបារាំង), ប្រតិចារឹកសវនាការ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ **E1/95.1** ទំព័រ ១១៩ បន្ទាត់ ២-១៩ (ភាសាបារាំង)) ធៀបនឹងកិច្ចព្រមព្រៀងសម្រាប់សហព្រះរាជអាជ្ញា (ឧទាហរណ៍ សូមមើលប្រតិចារឹកសវនាការ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/211.1** ទំព័រ ៩០ បន្ទាត់ ២៥ ដល់ទំព័រ ៩២ បន្ទាត់ ១៣ (ភាសាបារាំង), ប្រតិកម្មភ្លាមៗនិងឯកឯងរបស់អង្គជំនុំជម្រះ នៅក្នុងអំឡុងពេលសួរចម្លើយសាក្សីដាក់បន្ទុកម្នាក់ដោយសហព្រះរាជអាជ្ញា (ឧទាហរណ៍ សូមមើលប្រតិចារឹកសវនាការ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០១ ឯកសារ **E1/100.1** ទំព័រ ៥៧ បន្ទាត់ ៦-២០ (ភាសាបារាំង)) ធៀបនឹង ការពុំមានប្រតិកម្ម នៅក្នុងអំឡុងពេលសួរសំណួរសាក្សីដោះបន្ទុកម្នាក់ដោយសហព្រះរាជអាជ្ញា (ឧទាហរណ៍ សូមមើលប្រតិចារឹក ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/205.1** ទំព័រ ១០១-១០៦ (ភាសាបារាំង))។

[110] សំណើរបស់មេធាវីការពារក្តីលោក ខៀវ សំផន សុំបំភ្លឺអំពីកាលវិភាគនៃការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ **E295/1**។

ការថ្លែងរបស់មេធាវីការពារក្ដីពីសំណាក់អង្គជំនុំជម្រះ។ វាក៏បានបង្ហាញឱ្យឃើញផងដែរថា ជញ្ជីងបានផ្អៀងទៅរកខាងសហព្រះរាជអាជ្ញា។

១០១. ជាសរុបមក អង្គជំនុំជម្រះបានរំលោភយ៉ាងធ្ងន់ធ្ងរ និងជាក់ស្ដែងទៅលើសិទ្ធិជាមូលដ្ឋានរបស់លោក ខៀវ សំផន ក្នុងការទទួលបានសន្តិសុខគតិយុត្តិ ត្រូវបានជូនដំណឹងអំពីការចោទប្រកាន់ប្រឆាំងមកលើរូបគាត់ ទទួលបានពេលវេលា មធ្យោបាយចាំបាច់នានាសម្រាប់ត្រៀមរៀបចំការពារក្ដីរបស់ខ្លួន ទទួលបានការជំនុំជម្រះក្ដីដោយចំពោះមុខ ត្រូវបានគេស្ដាប់ចម្លើយ និងជំនុំជម្រះក្ដីដោយតុលាការអនាគតិ។ ចរិតលក្ខណៈដែលមិនអាចទទួលយកបាននៃការរំលោភទាំងនេះមានលក្ខណៈកាន់តែធ្ងន់ធ្ងរ ខណៈដែលគេសង្កេតឃើញថាអង្គជំនុំជម្រះពុំមានសមត្ថភាព និងឆន្ទៈក្នុងការគោរពតាមការណែនាំរបស់តុលាការកំពូល ដែលអង្គជំនុំជម្រះមានបំណងយកមកអនុវត្តទៅលើអង្គហេតុដែលបានកើតឡើង[111]។

## III. <u>អំពីការតព្វកិច្ចក្នុងការបញ្ចប់កិច្ចដំណើរការនីតិវិធី</u>

១០២. នៅចំពោះមុខអង្គជំនុំជម្រះនេះ ដែលពុំមានបំណង និងចេតនាក្នុងការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ ការរំលោភលើសិទ្ធិរបស់លោក ខៀវ សំផន បានធ្វើឱ្យលោកបាត់បង់លទ្ធភាពក្នុងការការពារខ្លួន ក្នុងក្របខណ្ឌនៃសិទ្ធិដែលគាត់ត្រូវទទួលបានតាមផ្លូវច្បាប់។ វាគឺជាកាតព្វកិច្ចរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងការបញ្ឈប់នីតិវិធី និងបង្គាប់ឱ្យមានការដោះលែងរូបលោក ខៀវ សំផន ជាបន្ទាន់។

[111] *សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ (សេចក្ដីសង្ខេបនៃសំអាងហេតុ)* ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ **E284/4/7** កថាខណ្ឌ ៩, បណ្ដឹងសាទុក្ខរបស់លោក ខៀវ សំផន ប្រឆាំងទៅនឹងសេចក្ដីសម្រេចលើសំណើសុំដោះលែងឱ្យនៅក្រៅឃុំជាបន្ទាន់ ដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **E275/2/1** កថាខណ្ឌ ៦៨-៦៩, បណ្ដឹងសាទុក្ខជាបន្ទាន់របស់លោក ខៀវ សំផន ប្រឆាំងនឹងសេចក្ដីសម្រេចតាមរយៈអ៊ីម៉ែលរបស់អ្នកស្រី LAMB នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ **E264/1/2/1** កថាខណ្ឌ ២១, សារណាបន្ថែម ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **E264/1/2/1/1** កថាខណ្ឌ ១០-១២ និង ២៧។

## ហេតុដូច្នេះ

១០៣. មេធាវីការពារក្ដីលោក ខៀវ សំផន សូមស្នើសុំដល់អង្គជំនុំជម្រះតុលាការកំពូល៖

- មេត្តាសម្រេចសេចក្ដីជាបន្ទាន់
- បញ្ឈប់ជាបន្ទាន់នូវកិច្ចដំណើរការនីតិវិធី
- បង្គាប់ឲ្យមានការដោះលែងលោក ខៀវ សំផន ជាបន្ទាន់។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន | ភ្នំពេញ | |
| | មេធាវី Anta GUISSÉ | ភ្នំពេញ | |
| | មេធាវី Arthur VERCKEN | ប៉ារីស | |